សុខ ជម្ពូភាសី

# មាគ៌បដិបត្តិ



LC
294
SOK

ព.ស ២៥៥៥ គ.ស ២០១១

# មាគ៌ាបដិបត្តិ

## វត្តសំសមី

ថ្ងៃ០៥កើត ខែអាសាឍ ព.ស.២៥៥៥

**សុខ ធម្មភាសី**

ព្រះរាជាណាចក្រកម្ពុជា
110078/11
6
បណ្ណាល័យជាតិ

រក្សាសិទ្ធិ

ព.ស. ២៥៥៥ គ.ស. ២០១១

National Library of Cambodia
00026774

## ពាក្យថ្លែងអំណរគុណ

សូមថ្លែងអំណរគុណ ចំពោះឯកឧត្តម **ឆាន់ សារផាន** លោកជំទាវ **គាត កុលណី** លោក **ឈួន ខួនស្រ៊ួយ** និងលោកស្រី **អ៊ុខ ម៉ុយគៀខ** យ៉ាងក្រៃលែង។

អាត្មាភាពសូមកោតសរសើរនឹងទឹកចិត្តសប្បុរស ដែលបានជួយខ្នះខ្នែងក្នុងកិច្ចការធម្មទាន ទាំងកម្លាំងកាយនិងកម្លាំងចិត្ត ព្រមទាំងជួយឧបត្ថម្ភនូវថវិកាផ្ទាល់ខ្លួន ដើម្បីបោះពុម្ពសៀវភៅ **មាគ៌ាបដិបត្តិ**មួយនេះ។

ដើម្បីតបស្នងនឹងទឹកចិត្តសប្បុរស អាត្មាភាពសូមជូនពរ ឯកឧត្តម លោកជំទាវ លោក និងលោកស្រី សូមជួបប្រទះនឹងពុទ្ធទាំងបួនប្រការ **អាយុ វណ្ណៈ សុខៈ** និង **ពលៈ** ជានិច្ចនិរន្តរ៍តរៀងទៅ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ព្រៃវែងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១

## ប្រធានមន្ទីរអប់រំ យុវជន និងកីឡា

ជាបឋម ខ្ញុំព្រះករុណា សូមថ្លែងអំណរគុណដោយសោមនស្សក្រៃលែងចំពោះព្រះតេជព្រះគុណ **សុខ ធម្មភាសី** ដែលបានរៀបរៀងសៀវភៅមានចំណងជើងថា**មាគ៌ាបដិបត្តិ** ដែលជាព្រះហស្ថនិពន្ធ និង ស្រាវជ្រាវដោយព្រះតេព្រះជគុណផ្ទាល់ ដើម្បីអប់រំយុវជនឲ្យយល់កាន់តែច្បាស់អំពីសីលធម៌សង្គម។

ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាសូមថ្លែងនូវការ

កោតសរសើរ ចំពោះព្រះតេព្រះជគុណ ដែលបានខិតខំនិពន្ធ និងរៀបរៀងសៀវភៅនេះឡើង ចំកាលៈទេសៈ ដែលយុវជនរបស់យើងមួយចំនួនតូច កំពុងប្រឈមជាមួយនឹងបាតុភាពអសកម្មមួយចំនួននៅក្នុងសង្គមដូចជា បញ្ហាគ្រឿងញៀន គ្រឿងស្រវឹង អំពើពាលាអាវ៉ាសែ ភ្លើតភ្លើនជាមួយនឹងការរីកចំរើននៃសម័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា ភ្លេចបដិបត្តិនូវ សីលធម៌ក្នុងសង្គម ដែលនាំទៅដល់ការបាត់បង់នូវសណ្តាប់ធ្នាប់របៀបរៀបរយ និងតម្លៃនៃសង្គមជាតិ។

ស្នាព្រះហស្តរបស់ព្រះតេជគុណ នឹងបានជាប្រយោជន៍រួមចំណែកកសាងសង្គមជាតិ ដើម្បីអភិវឌ្ឍនិងសម្បូររុងរឿង។

ខ្ញុំព្រះករុណាសូមប្រគេនពរ ព្រះតេជព្រះគុណ សូមប្រកបដោយពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ហ៊ឹម_សុផល

# អារម្ភកថា

សៀវភៅ **មាគ៌ាបដិបត្តិ**ដែលលោកអ្នកកំពុងកាន់អាននេះ ស្មេរបានសរសេរផ្តោតលើសីលធម៌ជាធំ ស្មេរចង់ឲ្យមនុស្សទាំង អស់បានយល់ច្បាស់ពីគុណវិបត្តិនៃការមិន បដិបត្តិសីល-ធម៌ និងគុណសម្បត្តិនៃការ បដិបត្តិសីលធម៌។

សៀវភៅនេះសរសេរឡើងក្នុងគោលបំណងជួយអប់រំដល់យុវវ័យ ឲ្យយល់ច្បាស់សីលធម៌នៅក្នុងសង្គម និងសីលធម៌នៅក្នុងគ្រួសារ។ ដូចគ្នានេះដែរ ស្មេរចង់អប់រំដល់គូស្វាមីភរិយាដែលទើបរៀបការថ្មីៗ ឲ្យយល់ពីសីលធម៌រស់នៅក្នុងគ្រួសារផងដែរ។ ស្មេរបានសរសេរវាជាអត្ថបទ មានវែងខ្លះខ្លីខ្លះសូមអ្នកអានទាំងឡាយមេត្តាអានឲ្យចប់នូវអត្ថបទនីមួយៗ ដើម្បីបានយល់ច្បាស់ពីអត្ថន័យនៅក្នុង

សៀវភៅនេះ។ សៀវភៅមាគ៌ាបដិបត្តិ ជាស្នាដៃដំបូងរបស់ស្មេរ ស្មេរយល់ឃើញថា ភាពខ្វះចន្លោះដោយអត្ថន័យ ឬអក្ខរាវិរុទ្ធអាចនឹង មានដោយអចេតនានៅក្នុងសៀវភៅនេះ។

ហេតុនេះ សូមអ្នកអានទាំងឡាយ មេត្តាអធ្យាស្រ័យរាល់ការខ្វះចន្លោះដោយអចេតនាដែលកើតមាន ស្មេរសូមទទួលនូវមតិរិះគន់ ក្នុងន័យស្ថាបនាពីមិត្តអ្នកអានទាំងឡាយ ដោយសោមនស្ស។

# នាមអ្នកជួយត្រួតពិនិត្យ

១- ព្រះព្រហ្មបញ្ញា **ស៊ុន-ច័ន្ទសុធា**

២- ព្រះមហា **វិមុត**

៣- ព្រះកោសលមុនី **បៀវ-ថាន**

៤- ព្រះមហា **យ៉ាំ-ផូរ**

៥- ព្រះមហា **ឆាត់-សុចេត**

៦- ព្រមហា **ប៉ែន-វិបុល**

៧- ឯកឧត្តម **ម៉ម-ឆៃ**

៨- លោកគ្រូ **ទូច-គីមស្រ៊ាង**

៩- លោកគ្រូ **សឿន-ប៊ុនធឿន**

១០- លោកគ្រូ **ប៉ាត់-ឈឿន**

បច្ចេកទេសកុំព្យូទ័រ យុវសិស្ស **គេង-សិរី**

# មាតិកា


ចំណងជើងអត្ថបទ ទំព័រ

១- ពាក្យប្រារព្ធ..............................១

២- តម្រូវការ...................................៤

៣- សីលធម៌...................................៩

៤- សហគមន៍ខ្មោចនិងទេវតា............៣៣

៥- អ្នកធំ...................................... ៣៨

៦- លេខ១និងលេខ២..................... ៤៩

៧- កំណាព្យ អដ្ឋបើ........................ ៦៩

៨- កំណាព្យ បណ្តាំម៉ែ...................... ៧០

៩- កំណាព្យ គ្រួសារបីយ៉ាង.............. ៧៥

# ពាក្យប្រារព្ធ

ជីវិតរបស់មនុស្សគ្រប់រូបតែងតែវិវឌ្ឍទៅមុខជានិច្ចឥតឈប់ឈរ ការវិវឌ្ឍទៅនៃមនុស្សទាំងអស់នោះ រមែងទទួលបានផលខុសៗគ្នា។ អ្នកធ្វើល្អតែងទទួលបានផលល្អ អ្នកធ្វើអាក្រក់តែងទទួលបានផលអាក្រក់ ព្រោះសត្វលោកមានកម្មជាអ្នកចាត់ចែង(ការប្រព្រឹត្ត) ។

ទង្វើគឺជាការបដិបត្តិ អំពើល្អនិងអំពើអាក្រក់ ជាមាគ៌ាសម្រាប់មនុស្សធ្វើដំណើរទៅរកសេចក្តីសុខនិងសេចក្តីទុក្ខ។ បើមនុស្សកាន់យកនូវអំពើល្អ ឈ្មោះថាជាអ្នកដើរទៅរកផ្លូវត្រូវគឺសុគតិ។ បើមនុស្សកាន់យកនូវអំពើអាក្រក់ឈ្មោះ ថាជាអ្នកដើរទៅរកផ្លូវខុសគឺទុគ្គតិ។

ល្អនិងអាក្រក់ ជាមាគ៌ាពីរផ្ទុយគ្នា មនុស្ស

គ្រប់រូបតែងបដិបត្តិមកជារៀងរាល់ថ្ងៃ។ មនុស្សល្អតែងតែបដិបត្តិទៅរកផ្លូវត្រូវ រីឯមនុស្សអាក្រក់តែងតែបដិបត្តិទៅរកផ្លូវខុស ព្រោះល្អនិងអាក្រក់មិនបានកើតចេញពីកំណើតមកទេ គឺកើតចេញមកពីការបដិបត្តិរបស់បុគ្គលម្នាក់ៗរៀងៗខ្លួន។

មនុស្សល្អមិនបានកើតចេញពីផ្ទៃម្តាយមកល្អតែម្តងនោះទេ រីឯមនុស្សអាក្រក់ក៏មិនបានកើតចេញពីផ្ទៃម្តាយមកអាក្រក់តែម្តងនោះក៏ទេដែរ។

មនុស្សល្អនិងមនុស្សអាក្រក់មានការបដិបត្តិជាអ្នកតាក់តែង មិនមែនព្រហ្មលិខិតជាអ្នកតាក់តែងទេ ឬថាព្រះណាមួយជាអ្នកតាក់តែងនោះក៏ទេដែរ។

មនុស្សគ្រប់រូបជាអ្នកតាក់តែងនិងកំណត់ជីវិតដោយខ្លួនឯង មិនមានអ្នកណាជាអ្នកតាក់

តែងនិងកំណត់ឲ្យទេ បើមនុស្សចង់ល្អត្រូវបដិបត្តិទៅរកផ្លូវល្អដោយខ្លួនឯង អ្នកដទៃមិនអាចបដិបត្តិឲ្យយើងល្អបានទេ។

មាគ៌ាបដិបត្តិ គឺការចង្អុលប្រាប់ផ្លូវដល់សព្វសត្វទាំងអស់ឲ្យដើរទៅរកផ្លូវត្រូវ ជាផ្លូវនាំមកនូវភាពចម្រុងចម្រើន ភាពសុខដុមរមនា និងសុភមង្គលគ្រប់យ៉ាងដល់មនុស្សលោក។

ម្យ៉ាងវិញទៀត មាគ៌ាបដិបត្តិ ក៏មានតួនាទីដឹកនាំសព្វសត្វទាំងអស់ ឲ្យព្យាយាមដើរចេញពីផ្លូវខុស ដែលជាផ្លូវនាំទៅរកតែសេចក្តីវិនាសអន្តរាយ សេចក្តីទុក្ខវេទនា និងអពមង្គលគ្រប់យ៉ាងក្នុងជីវិតផងដែរ។

ព្រៃវែងវត្តសំសមីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១

**សុខ ធម្មភាសី**

# តម្រូវការ

ស្មៅជាតម្រូវការរបស់សត្វគោ កន្ទក់ជាតម្រូវការរបស់សត្វជ្រូក ទឹកជាតម្រូវការរបស់សត្វត្រី ព្រៃជាតម្រូវការរបស់សត្វព្រៃទាំងអស់នៅក្នុងលោក។

ចុះអ្វីទៅជាតម្រូវការរបស់មនុស្ស? បើយើងនិយាយពីតម្រូវការរបស់មនុស្ស មនុស្សរកកំណត់ថា មានតម្រូវការអ្វីឲ្យពិតប្រាកដនោះមិនបានឡើយ ព្រោះមនុស្សជាប្រភេទសត្វម្យ៉ាងដែលមានតម្រូវការច្រើនជាងសត្វណាៗទាំងអស់នៅក្នុងលោក។

មនុស្សជាអ្នកកែច្នៃធម្មជាតិឲ្យប្លែកចាកពីសភាពដើមដើម្បីបំពេញនូវតម្រូវការរបស់ខ្លួនដោយលោភៈនៃចិត្ត មនុស្សហ៊ានធ្វើអ្វីៗគ្រប់

យ៉ាង មិនថាការងារនោះមានផលប៉ះពាល់ទៅដល់ភពផែនដី ឬដល់អ្នកដទៃយ៉ាងណានោះទេ មនុស្សហ៊ានធ្វើទាំងអស់។

កាលដែលមនុស្សហ៊ានធ្វើនូវការងារទាំង-អស់នោះ ដោយពួកគេមើលឃើញនូវតម្រូវការតែម្យ៉ាងគត់គឺ **លុយ** ពួកគេបាននិយាយថា «**មានលុយ គឺមានអ្វីៗគ្រប់យ៉ាងទាំងអស់**»។

តើលុយពិតជាតម្រូវការគ្រប់យ៉ាងទាំងអស់របស់មនុស្សមែនឬ?

យោងទៅលើទិដ្ឋភាពនៅក្នុងសង្គមសព្វថ្ងៃ ប្រហែលជាពិត ព្រោះលុយអាចទិញអ្វីៗបានគ្រប់យ៉ាងទាំងអស់ពិតមែន (ទិញបានអ្វីៗដែលគេដាក់លក់នៅក្នុងទីផ្សារ) តែបើតាមទិដ្ឋភាពជាក់ស្តែង លុយមិនអាចទិញអ្វីៗបានគ្រប់យ៉ាង

ទាំងអស់ទេ ដូចជាជីវិត សេចក្ដីសុខ និងគុណ-ធម៌ លុយមិនអាចទិញបានឡើយ។

លុយគ្រាន់តែជាគ្រឿងអាស្រ័យ សម្រាប់ដោះស្រាយបញ្ហាឲ្យរួចបានម្ដងៗតែប៉ុណ្ណោះ។ លុយអាចទិញសេចក្ដីសុខក្រៅខ្លួនបាន តែលុយមិនអាចដោះស្រាយបញ្ហាបានគ្រប់រឿងទាំងអស់ទេ។ លុយគឺជាអំនួតខាងក្រៅរបស់មនុស្ស មនុស្សខ្លះមានលុយទុកគ្រាន់តែបង្អួតមហិច្ឆតាដាក់គ្នាតែប៉ុណ្ណោះ។ លុយប្រៀបដូចជាភ្លើងឬអាវុធមុខពីរ បើមនុស្សប្រើលុយមិនបានត្រឹមត្រូវល្អទេ លុយនឹងផ្ដល់សេចក្ដីទុក្ខសោកមកដល់មនុស្សវិញជាមិនខាន។

យ៉ាងនេះសបញ្ជាក់ឲ្យឃើញថា លុយមិនមែនជាតម្រូវការខ្លាំងណាស់សម្រាប់មនុស្សពេក-

ទេ លុយគ្រាន់តែជាគ្រឿងអាស្រ័យតែប៉ុណ្ណោះ។

លោក **ដ្វាយត៍ ដេវិដ អៃសិនហូវ័រ** (Dwight David Eisenhower) ប្រធានាធិបតីជំនាន់ទី៣៨ នៃសហរដ្ឋអាមេរិក បាននិយាយថា លុយនិងអាវុធ ពុំមែនជាតំណាងឲ្យខួរក្បាលនោះទេ តែវាជាតំណាងឲ្យអំណាច(Money and weapons are not representatives of brain, but they are those of the power.)។ នៅក្នុងព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធព្រះអង្គបានសន្មតថា មាសប្រាក់ លុយ គ្រាន់តែជាបច្ច័យ(គ្រឿងអាស្រ័យ)តែប៉ុណ្ណោះ ដើម្បីស្វែងរកសេចក្ដីសុខ មនុស្សគ្រប់រូបត្រូវតែអាស្រ័យនឹងបច្ច័យ៤[១] ប៉ុន្តែមានបច្ច័យ៤តែម្យ៉ាងមិនអាចធ្វើ

១ បច្ច័យ៤ជាតម្រូវការឲ្យរូបរាងកាយ=លុយ

ឲ្យយើងទទួលបាននូវសេចក្តីសុខទេ បើចង់ទទួលបាននូវសេចក្តីសុខ មនុស្សគ្រប់រូបត្រូវតែបដិបត្តិសីលធម៌ទៅជាមួយផង។

សីលធម៌ គឺជាតម្រូវការចាំបាច់មួយដែលមនុស្សមិនអាចខ្វះបាន មនុស្សត្រូវតែមានសីលធម៌ កាលបើមនុស្សមិនមានសីលធម៌ទេ មនុស្សប្រៀបដូចជាសត្វតិរច្ឆាន រកសេចក្តីសុខមកដាក់ខ្លួនមិនបានឡើយ។

ហេតុនេះ ដើម្បីទទួលបាននូវសេចក្តីសុខ មនុស្សគ្រប់រូបត្រូវតែបដិបត្តិសីលធម៌ ឲ្យបានជាប់លាប់ល្អជានិច្ច កុំបីប្រមាទធ្វេសឡើយ។

បក្សាបក្សីស្អាតព្រោះមានរោម
សត្វល្មនសមល្មមមានស្បែកស្រកា
ដំរីគោសេះល្អព្រោះខ្លាំងក្លា
មនុស្សក្នុងលោកាល្អព្រោះសីលធម៌។

# សីលធម៌

បើយើងមើលទៅលើពិភពលោកទាំងមូល យើងនឹងបានដឹងថា បណ្តាប្រទេសទាំងឡាយ នៅលើពិភពលោកយើងនេះ មានប្រទេសខ្លះមានសន្តិភាព ប្រទេសខ្លះនៅមិនទាន់មានសន្តិ-ភាពនៅឡើយទេ តែបើតាមការសិក្សាស្រាវជ្រាវមក អ្នកប្រាជ្ញទាំងឡាយគេបានដឹងថា ប្រទេសដែលមានសន្តិភាព គឺអាស្រ័យទៅលើប្រជាជនដែលមានសីលធម៌ ជាមួយគ្នានោះដែរ គ្រួសារដែលមានសុភមង្គល មិនមានវិវាទឈ្លោះទាស់ទែងគ្នា វាក៏អាស្រ័យទៅលើសីលធម៌នេះដែរ។

តើសីលធម៌មានន័យយ៉ាងណាទៅ? ហេតុអ្វីបានជាមានសារៈសំខាន់លើសង្គមមនុស្ស និង

សង្គមគ្រួសារខ្លាំងយ៉ាងនេះ?

ដើម្បីឲ្យងាយយល់ ទៅលើពាក្យថាសីលធម៌ រចនាករសូមញែកពាក្យនេះជាពីរឲ្យដាច់ចេញពីគ្នា គឺសីលមួយពាក្យ និងធម៌មួយពាក្យ។

ពាក្យថាសីល នៅក្នុងវចនានុក្រមខ្មែរបានពន្យល់ថា **វិរតិចេតនា ដែលវៀរចាកអំពើអាក្រក់ការកាន់ឬប្រព្រឹត្តល្អដោយកាយវាចា** សមដូចពាក្យខ្មែរយើងមួយឃ្លាថា **«ដើរឲ្យមានបីស្រដីឲ្យមានបួន»** គឺការប្រព្រឹត្តល្អដោយកាយវាចា ប្រព្រឹត្តល្អដោយកាយបីយ៉ាង និងប្រព្រឹត្តល្អដោយវាចាបួនយ៉ាង។

**ដើរឲ្យមានបី**

- មិនដើរទៅកាប់សម្លាប់មនុស្ស និងពពួកសត្វ។

- មិនដើរទៅលួចឆក់ប្លន់ទ្រព្យសម្បត្តិ របស់អ្នកដទៃ។
- មិនដើរទៅប្រព្រឹត្តអនាចារដោយការមេលើប្ដីប្រពន្ធកូនគេនិងកូនខ្លួនឯង។

## ស្រដីឲ្យមាន៤

- មិននិយាយពាក្យកុហកភូតភរធ្វើឲ្យអ្នកដទៃវិនាស។
- មិននិយាយញុះញង់ឲ្យអ្នកដទៃឈ្លោះទាស់ទែងគ្នា។
- មិននិយាយពាក្យទ្រគោះបោះបោក ជេរប្រទេចផ្ដាសាអ្នកដទៃ។
- មិននិយាយពាក្យឡេះឡោះឥតប្រយោជន៍។

ជាងនោះទៅទៀត នៅក្នុងវចនានុក្រមខ្មែរ ដដែលនោះបានពន្យល់ទៀតថា **មិនត្រូវប្រព្រឹត្ត កន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ**[១] មានន័យថា ដើម្បីឲ្យពេញទៅជាមនុស្សមួយរយភាគរយបាន មនុស្សត្រូវតែមានសីល គឺប្រព្រឹត្តិទៅតាមសិក្ខា-បទរបស់មនុស្សទាំងប្រាំ(សីល៥) បើប្រព្រឹត្តិមិន បានគ្រប់ទាំងប្រាំទេ ដាច់សិក្ខាបទណាមួយ ហើយនោះ ឲ្យឈ្មោះថា មានភាវៈជាសត្វតិរច្ឆាន ចូលមកនៅក្នុងខ្លួនចំនួន២០% បើដាច់ពីរ មាន ភាវៈជាសត្វតិរច្ឆាន៤០% បើដាច់បី មានភាវៈ ជាសត្វតិរច្ឆាន៦០% បើដាច់បួន មានភាវៈជា សត្វតិរច្ឆាន៨០% បើដាច់ប្រាំ មានភាវៈជាសត្វ

១ ការបញ្ញត្តវិន័យរបស់ព្រះសម្មាសម្ពុទ្ធ

តិរច្ឆាន១០០%។ ហេតុនេះគ្រប់មនុស្សទាំងអស់ត្រូវតែគោរពទៅតាមសិក្ខាបទទាំងប្រាំ ឲ្យបានត្រឹមត្រូវល្អជានិច្ចទើបឲ្យឈ្មោះថាពេញលក្ខណៈជាមនុស្សបាន១០០% ឬហៅថា មនុស្សទ្រូងប្រាំហត្ថ។

## សីល៥

១- វៀរចាកបាណាតិបាត គឺតាំងចិត្តសិក្សាថា អាត្មាអញមិនសម្លាប់មិនបៀតបៀនជីវិតមនុស្សនិងជីវិតសត្វទាំងអស់។

២-វៀរចាកអទិន្នាទាន គឺតាំងចិត្តសិក្សាថាអាត្មាអញមិនកាន់យកនូវទ្រព្យសម្បត្តិ ដែលម្ចាស់គេមិនបានឲ្យដោយកាយ ឬដោយវាចាឡើយ។

៣- វៀរចាកកាមេសុមិច្ឆាចារ គឺតាំងចិត្តសិក្សាថា អាត្មាអញមិនប្រព្រឹត្តខុសក្នុងកាម មិនប្រទូសរ៉ាយចំពោះអ្នកដទៃ ដោយការរំលោភបំពានលើស្ត្រីដែលគេហួងហែង។ អាត្មាអញត្រូវតែជាអ្នកប្រព្រឹត្តស្មោះត្រង់រវាងភរិយាស្វាមី រក្សាវង្សត្រកូលកិត្តិយសរបស់ខ្លួន និងកិត្តិយសអ្នកដទៃឲ្យបានល្អ។

៤- វៀរចាកមុសាវាទ គឺតាំងចិត្តសិក្សាថា អាត្មាអញមិននិយាយពាក្យកុហក សូម្បីតែពាក្យកុហកដើម្បីសើចលេង។

៥- វៀរចាកសុរានិងមេរ័យ គឺតាំងចិត្តសិក្សាថា អាត្មាអញមិនបរិភោគនូវទឹកស្រវឹង និងគ្រឿងញៀនទាំងឡាយ ដែលជាហេតុធ្វើឲ្យអាត្មាអញក្លាយទៅជាមនុស្សកាចសាហាវ និងជាហេតុធ្វើ

ឲ្យអាត្មាអញចុះខ្សោយស្មារតី។

សីល គឺការកាន់ចរិយាល្អ ការសង្រួម អង្គនៃចរិយា ចរិតមារយាទល្អ សេចក្ដីល្អ និស្ស័យ អធ្យាស្រ័យ សភាពប្រក្រតី ដែលគ្រប់មនុស្សទាំងអស់ ត្រូវតែកាន់យកមកដាក់នៅក្នុងខ្លួន ហើយបដិបត្តិតាមឲ្យបានល្អជានិច្ចកាល កុំបីប្រមាទធ្វេសប្រហែសឡើយ។

ពាក្យថា ធម៌ គឺជាសភាវៈដែលកើតឡើងដោយឯងៗ ជាធម្មជាតិដែលប្រព្រឹត្តទៅតាមហេតុផលពិតៗ គ្មានព្រះណាមួយជាអ្នកបង្កើតមកទេ ធម៌បានកើតឡើងទៅតាមសភាវៈធម្មតារបស់ធម្មជាតិ មានជាយូរណាស់មកហើយ។

នៅក្នុងវចនានុក្រមខ្មែរបានពន្យល់ថា ធម៌ គឺសភាវៈដែលទ្រទ្រង់សត្វលោក គឺជាបុណ្យ,

បាប, សុចរិត, ទុច្ចរិត មកពីពាក្យបាលីថា ធម្មៈ មានន័យថា ហេតុ សភាព ធម្មតា ធម្មជាតិ ប្រាជ្ញាញាណ គុណ សេចក្តីចម្រើន អារម្មណ៍ ខាងក្នុងចិត្ត ការរិះគិត សង្ខារ កិរិយាមារយាទ បរិយត្តិ ច្បាប់។ ពាក្យនេះ គឺជាសភាវៈធម្មតា កើតចេញពីធម្មជាតិ មានទាំងល្អ មានទាំង អាក្រក់ ធម៌ជាកុសល ធម៌ជាអកុសល ឬថាធម៌ ជាអព្យាក្រឹត វាអាស្រ័យទៅលើការប្រព្រឹត្តរបស់ មនុស្ស បើមនុស្សប្រព្រឹត្តល្អ អំពើល្អនោះ ជា កុសលធម៌ បើមនុស្សប្រព្រឹត្តអាក្រក់ អំពើ អាក្រក់នោះ ជាអកុសលធម៌ បើមនុស្សប្រព្រឹត្ត ជាកណ្តាលៗ ដែលមិនអាចកំណត់បានថាល្អឬ អាក្រក់នោះ ជាអព្យាកតធម៌(ធម៌ជាអព្យាក្រឹត)។

មនុស្សដែលកើតមកមានបញ្ញាញាណ និង

កិរិយាមារយាទល្អ គឺអាស្រ័យទៅលើការចិញ្ចឹមបីបាច់ថែរក្សាពីឪពុកម្តាយបានល្អ រួមជាមួយនឹងឧបនិស្ស័យនិងការប្រតិបត្តិ ដែលបានសន្សំទុកមកកាលពីអតីតផង។

ផែនដីតែមួយ រុក្ខជាតិដុះចេញមកមានទ្រង់ទ្រាយពណ៌សម្បុរនិងរសជាតិខុសៗគ្នា ដើមស្មៅដុះចេញមក ល្វីងទាំងស្លឹកល្វីងទាំងផ្កា ដើមមៀនដុះចេញមក ផ្លែមានរសជាតិផ្អែមឈ្ងុយឆ្ងាញ់ ទាំងនេះវាមិនមែនបណ្តាលមកពីផែនដីទេ គឺវាអាស្រ័យទៅលើពូជនៃធម្មជាតិរបស់រុក្ខជាតិ។

មេជ្រូកតែមួយ កូនចេញមកមានពណ៌សម្បុរទ្រង់ទ្រាយនិងមាឌខុសៗគ្នា ទាំងនេះវាក៏មិនមែនបណ្តាលមកពីមេជ្រូកដែរ គឺវាអាស្រ័យទៅលើធម្មជាតិរបស់កូនជ្រូក។

យ៉ាងណាមិញ ម្ដាយតែមួយ ពេលមានកូន កូនទាំងនោះ មានស មានខ្មៅ មានល្អមានអាក្រក់ មានតូចមានធំ មានទ្រង់ទ្រាយមុខមាត់ខុសៗគ្នា មិនដូចគ្នាទេ កូនខ្លះស្រួលទូន្មានប្រៀនប្រដៅ តែកូនខ្លះទូន្មានប្រៀនប្រដៅមិនបាន ទាំងនេះវាមិនមែនបណ្ដាលមកពីការពពោះរបស់ម្ដាយនោះទេ គឺបណ្ដាលមកពីការប្រព្រឹត្តរបស់កូននោះដោយខ្លួនឯង និងបណ្ដាលមកពីធម្មជាតិរបស់កូន ដែលកើតមានមកតាំងពីកំណើត មិនមានអ្នកណាជាអ្នកបញ្ញត្ត ឬលិខិតឲ្យវាទេ បើវាប្រឹងសន្សំពូជល្អ គឺវានឹងល្អដោយខ្លួនឯង បើវាប្រឹងសន្សំពូជអាក្រក់ គឺវានឹងអាក្រក់ដោយខ្លួនឯង គ្មានម្ដាយណាចង់ឲ្យកូនរបស់ខ្លួនអាក្រក់នោះទេ តែទោះជាកូនរបស់គាត់កើតមក

មានសភាពអាក្រក់យ៉ាងណាក៏ដោយ ក៏ម្តាយគ្រប់រូបនៅតែស្រលាញ់កូនដែរ។ ទាំងនេះគឺជាធម្មជាតិរបស់ម្តាយគ្រប់រូប មិនមានម្តាយណាមួយ ស្អប់កូនរបស់ខ្លួនឯងនោះទេ។

សភាវធម៌ទាំងអស់នេះ គឺកើតមានឡើងនៅលើពិភពលោកយើងនេះទាំងអស់ កើតមានមកដោយឯងៗ មិនមានអ្នកណាជាអ្នកបង្កើត ជាអ្នកលិខិត ឬជាអ្នកបញ្ញត្តវាទេ គឺជាសភាវៈធម្មតារបស់សត្វលោក របស់ភពផែនដីនិងធម្មជាតិ ទាំងអស់នេះកើតមានតាំងតែពីយូរណាស់មកហើយ នេះជាធម្មជាតិ ធម្មជាតិគឺជាធម្មៈធម្មៈគឺជាធម៌។

សីលធម៌ គឺជាសីលដែលជាធម៌របស់សត្វលោក ជាធម៌ដែលដឹកនាំមនុស្សឲ្យមានកិរិយា

មារយាទល្អ មានសណ្ដាប់ធ្នាប់ល្អ។ គឺជាដំបូន្មាន ដែលដឹកនាំមនុស្សឲ្យវៀរចាកអំពើអាក្រក់ ហើយ ប្រព្រឹត្តតែអំពើល្អ ធ្វើល្អជានិច្ចកាលដោយកាយ វាចាចិត្ត។ សីលធម៌ ជាមាគ៌ាដឹកនាំមនុស្សឲ្យ ចេះស្មោះត្រង់ ចេះស្រលាញ់រវាងគ្នានិងគ្នា ជា សភាវៈធ្វើឲ្យសង្គមជាតិ និងសង្គមគ្រួសារ មាន នូវសុខសន្តិភាព និងសុភមង្គល។

វាជាការពិត អ្នកណាៗក៏ត្រូវការធម៌ដែរ ពីព្រោះថា ធម៌គឺជាសភាវៈដែលទ្រទ្រង់សត្វ លោកឲ្យខ្ពង់ខ្ពស់ ឲ្យចម្រុងចម្រើន ឲ្យមានសិរី-សួស្ដី មានកិត្តិយសកេរ្តិ៍ឈ្មោះ។ ធម៌ដឹកនាំ មនុស្សអាក្រក់ ឲ្យក្លាយទៅជាមនុស្សល្អរស់នៅ ក្នុងសង្គមបាន តែនៅពេលដែលពួកមនុស្សបាន ឮពាក្យថាធម៌ ហេតុអ្វី? ពួកគេនាំគ្នាស្អប់ធម៌ខ្លាច

ធម៌ និងគិតទៅដល់ព្រះធម៌ដែលគេសូធ្យនៅក្នុងវត្តទៅវិញ។ តាមពិតទៅ ធម៌នៅក្នុងវត្តក្តី នៅក្រៅវត្តក្តី គឺសុទ្ធតែជាធម៌ទាំងអស់ ធម៌នៅក្នុងទីនេះគឺសីលធម៌។

មកដល់ត្រង់នេះ មនុស្សទាំងឡាយប្រហែលជាមាននូវចម្ងល់ថា ហេតុអ្វីបានជាធម៌ទីនេះក្លាយទៅជាសីលធម៌យ៉ាងនេះទៅវិញ?

បានជាធម៌ក្លាយទៅជាសីលធម៌យ៉ាងនេះ ព្រោះថា អ្នកដែលមានសីល ប្រតិបត្តិបានត្រឹមត្រូវទៅតាមសីល ត្រូវទៅតាមសិក្ខាបទទាំងប្រាំនៃសីល គឺឲ្យឈ្មោះថា ជាអ្នកមានធម៌ ឬថាជាអ្នកប្រតិបត្តិត្រូវទៅតាមកុសលធម៌ ជាអ្នកដែលបានវៀរចាកនូវអំពើអាក្រក់ ដែលមនុស្សសាមញ្ញទាំងឡាយនាំគ្នាហៅថា ជាអ្នកមានសីលធម៌

ហ្នឹងឯង។

ធម៌មិនមែនជាខ្លា ដែលចាំដេញខាំស៊ីសាច់មនុស្សឯណា ហេតុអ្វីក៏មនុស្សនាំគ្នាស្អប់ធម៌ខ្លាចធម៌យ៉ាងនេះទៅវិញ? ទាំងដែលយើងទាំងអស់គ្នាដឹងហើយថា បើយើងមិនមានធម៌នៅក្នុងខ្លួនទេ យើងនឹងក្លាយទៅជាមនុស្សអាក្រក់មួយរំពេចចុះហេតុអ្វីបានជាយើងនាំគ្នា ស្អប់ធម៌ខ្លាចធម៌យ៉ាងនេះទៅវិញ? តើយើងបានដឹងទេ មនុស្សបើគ្មានធម៌គឺជាសត្វតិរច្ឆាន?

នៅក្នុងសៀវភៅស្រីហិតោបទេសលោកបានសរសេរថា **ការបរិភោគអាហារ១ ការដេក១ ភ័យ១ និងសេពមេថុន១ ទាំង៤ប្រការនេះមនុស្សនិងសត្វមានស្មើគ្នា មានតែព្រះធម៌ប៉ុណ្ណោះទេ ទើបអាចធ្វើមនុស្សនិងសត្វឲ្យ**

វិសេសប្លែកពីគ្នាបាន នរណាប្រាសចាកធម៌ អ្នកនោះឯងទុកស្មើសត្វ។

វាជាការពិតណាស់ កាលណានៅក្នុងសង្គមជាតិមួយ ឬសង្គមគ្រួសារមួយ ប្រាថ្នាចង់បាននូវសេចក្តីសុខសន្តិភាព និងសុភមង្គលបណ្តាមនុស្សទាំងអស់នោះ ត្រូវតែយកធម៌មកដាក់នៅក្នុងខ្លួន ទើបមនុស្សទាំងនោះ អាចទទួលបាននូវសេចក្តីសុខសន្តិភាព និងសុភ-មង្គល។

នៅក្នុងសៀវភៅស្រីហិតោបទេសដដែលសរសេរថា«ម្រឹគមិនដែលបោលចូលមាត់សីហៈដែលកំពុងតែដេកលក់នោះទេ» ដូចគ្នានោះដែរអាហារក៏វាមិនអាចចូលមកឲ្យយើងឆ្អែតបានដែរបើយើងមិនបរិភោគវាទេនោះ យ៉ាងណាមិញ

ធម៌ក៏មិនបានចូលមករកមនុស្សដែរ កាលបើមនុស្សមិនប្រព្រឹត្តធម៌ទេ មនុស្សនៅតែជាមនុស្សអធម៌ អាក្រក់ដដែល។

លោក ចច **វ៉ាស៊ិនតោន** (Goerge Washington) ដែលជាអ្នកទាមទារ ឯករាជ្យឲ្យមកសហរដ្ឋអាមេរិក ពីអាណានិគមរបស់ចក្រភពអង់គ្លេស និងជាប្រធានាធិបតីទី១ នៅក្នុងសហរដ្ឋអាមេរិក បាននិយាយថា **ការប្រព្រឹត្តខុសគឺជារឿងធម្មតា តែការកែលម្អកំហុស គឺជាសេចក្តីក្លាហានអង់អាច** (To do mistakes is simple, to correct mistakes is glorious.) លោកបានបន្តទៅទៀតថា **សេចក្តីសុខនិងទង្វើប្រកបដោយគុណធម៌របស់មនុស្ស វាតែងតែផ្សារភ្ជាប់ជាមួយគ្នាយ៉ាងជិតស្និទ្ធ មិនអាចញែកចេញពីគ្នាបាន**

ឡើយ (The human beings' happiness and moral practice are in an inseparable connection.) យ៉ាងណាមិញ សេចក្ដីសុខរបស់សង្គមជាតិនិងសង្គមគ្រួសារ ត្រូវតែផ្សារភ្ជាប់ជាមួយគ្នាជានិច្ចនិងសីលធម៌ បើសង្គមជាតិមិនមានសីលធម៌ទេ សង្គមគ្រួសារមិនមានសីលធម៌ទេ អំពើហិង្សា ការឈ្លោះទាស់ទែងគ្នា ការកាប់សម្លាប់គ្នា រមែងកើតឡើងគ្រប់ពេលវេលា។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់បានប្រកាសសម្ដែងថា «ម្នាលភិក្ខុទាំងឡាយ សម័យណាពួកព្រះរាជាមិនប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការក៏មិនប្រកបដោយធម៌ដែរ។

ម្នាលភិក្ខុទាំងឡាយ កាលពួកអ្នករាជការមិនប្រកបដោយធម៌ ពួកព្រាហ្មណ៍ និងគហបតី

ក៏មិនប្រកបដោយធម៌ដែរ។ កាលពួកព្រាហ្មណ៍និងគហបតី មិនប្រកបដោយធម៌ហើយ សម័យនោះពួកអ្នកនិគម និងអ្នកជនបទ មិនប្រកបដោយធម៌ដែរ។ កាលអ្នកនិគមនិងអ្នកជនបទមិនប្រកបដោយធម៌ហើយ ព្រះចន្ទ្រនិងព្រះអាទិត្យ ក៏គោចរទៅមិនស្មើដែរ។ កាលបើព្រះចន្ទ្រនិងព្រះអាទិត្យ គោចរទៅមិនស្មើ ពួកផ្កាយនក្ខត្តឫក្ស ក៏គោចរទៅមិនស្មើដែរ។ កាលពួកផ្កាយនក្ខត្តឫក្ស គោចរទៅមិនស្មើ យប់និងថ្ងៃក៏ប្រព្រឹត្តទៅមិនស្មើដែរ។ កាលយប់និងថ្ងៃ ប្រព្រឹត្តទៅមិនស្មើ ខែនិងកន្លះខែ ក៏ប្រព្រឹត្តទៅមិនស្មើដែរ។ កាលបើខែនិងកន្លះខែ ប្រព្រឹត្តទៅមិនស្មើ រដូវនិងឆ្នាំ ក៏ប្រព្រឹត្តមិនស្មើដែរ។ កាលបើរដូវនិងឆ្នាំ ប្រព្រឹត្តទៅមិនស្មើ ខ្យល់ក៏បក់មិន

ស្មើដែរ។ កាលខ្យល់បក់មិនស្មើ ខ្យល់បក់ខុសរដូវទាំងឡាយ ក៏ប្រព្រឹត្តទៅមិនស្មើដែរ។ កាលខ្យល់បក់ខុសរដូវទាំងឡាយ ប្រព្រឹត្តទៅមិនស្មើ ទេវតាទាំងឡាយក៏ខឹងសំបា។ កាលទេវតាទាំងឡាយខឹងសំបា ភ្លៀងក៏មិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ។ កាលភ្លៀងមិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ស្រូវទាំងឡាយក៏ឲ្យផលមិនស្មើល្អ។

ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សកាលបើបរិភោគស្រូវដែលឲ្យផលមិនស្មើល្អ រមែងមានអាយុខ្លី មានសម្បុរអាក្រក់ មានកម្លាំងតិច មានអាពាធច្រើន។

ម្នាលភិក្ខុទាំងឡាយ សម័យណា ពួកព្រះរាជាប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការ

ក៏ប្រកបដោយធម៌ដែរ។ កាលបើពួកខ្ញុំរាជការប្រកបដោយធម៌ ។ល។ កាលបើផ្លូវខ្យល់ទាំងឡាយស្មើ ពួកទេវតាទាំងឡាយមិនខឹងសំបា កាលពួកទេវតាទាំងឡាយមិនខឹងសំបា ភ្លៀងក៏បង្អុរទឹកភ្លៀង ចុះមកដោយប្រពៃ។ កាលភ្លៀងបង្អុរទឹក ភ្លៀងចុះមកដោយប្រពៃ ស្រូវក៏ឲ្យផលស្មើ ល្អ។

ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយកាលបរិភោគស្រូវដែលមានផលស្មើល្អរមែងមានអាយុវែង មានសម្បុរល្អ មានកម្លាំង ព្រមទាំងមានអាពាធតិច»។

ដូចគ្នានេះដែរ គ្រួសារមួយ ប្តីប្រពន្ធមិនមានសីលធម៌ កូនទាំងឡាយក៏មិនមានសីលធម៌ដែរ។ កូនទាំងឡាយមិនមានសីលធម៌ ចៅទាំង-

ឡាយក៏មិនមានសីលធម៌ដែរ។ ចៅទាំងឡាយមិនមានសីលធម៌ ចៅទួតទាំងឡាយក៏មិនមានសីលធម៌ដែរ។ កាលបើពួកចៅទួតទាំងឡាយមិនមានសីលធម៌ ពួកអ្នកស្រុកអ្នកភូមិគេរមែងស្អប់មិនចូលចិត្ត។ កាលពួកអ្នកស្រុកអ្នកភូមិគេស្អប់មិនចូលចិត្ត ភាពកំណាញមិនចែកទានរមែងកើតឡើង។ កាលបើការកំណាញ់មិនចែកទានកើតឡើង ការលួចឆក់ប្លន់ក៏កើតឡើងដែរ។ កាលបើការលួចឆក់ប្លន់កើតឡើង គ្រឿងសស្ត្រាវុធក៏កើតឡើងដែរ។ កាលបើគ្រឿងសស្ត្រាវុធកើតឡើង ការកាប់សម្លាប់គ្នាក៏កើតឡើងដែរ។ កាលបើការកាប់សម្លាប់កើតឡើង ការនិយាយកុហកក៏កើតឡើងដែរ។ កាលបើការនិយាយកុហកកើតឡើង ការនិយាយចាក់ចុចកើតឡើង

ការប្រព្រឹត្តិខុសប្រពៃណីកើតឡើង ការនិយាយអាក្រក់និងនិយាយមិនបានការកើតឡើង ការគិតចង់បានរបស់គេនិងគិតព្យាបាទគេកើតឡើង ការយល់ខុសកើតឡើង អធម្មរាគៈ វិសមលោភៈ មិច្ឆាធម្មៈកើតឡើង ពេលនោះការគោរពក៏លែងមាន ពណ៌សម្បុររបស់មនុស្សក៏ថយចុះ មនុស្សមានអាយុខ្លី។

អស់លោកទាំងឡាយ កាលបើគ្រួសារមួយប្តីប្រពន្ធជាអ្នកមានសីលធម៌ កូនទាំងឡាយក៏មានសីលធម៌ដែរ។ កាលបើកូនទាំងឡាយមានសីលធម៌ ចៅទាំងឡាយក៏មានសីលធម៌ដែរ។ កាលបើចៅទាំងឡាយមានធម៌។ល។ ការនិយាយចាក់ចុចលែងកើតមាន ការប្រព្រឹត្តខុសប្រពៃណីលែងកើតមាន ការនិយាយអាក្រក់និង

និយាយមិនបានការលែងកើតមាន ការគិតចង់បានរបស់គេនិងគិតព្យាបាទគេលែងកើតមាន មានការយល់ត្រូវ អធម្មរាគៈ វិសមលោភៈ មិច្ឆាធម្មៈលែងកើតមាន ពេលនោះការគោរពក៏កើតឡើង មនុស្សមានពណ៌សម្បុរល្អ មានអាយុវែង។

អស់លោកទាំងឡាយ ទាំងអស់នេះគឺជាផលនៃសីលធម៌ សីលធម៌នាំមកនូវប្រយោជន៍ដ៏ច្រើនដល់មនុស្សលោក មនុស្សលោកមិនអាចរស់នៅដោយគ្មានសីលធម៌បានឡើយ កាលបើពិភពលោក គ្មានសីលធម៌ ពិភពលោកនឹងសាបសូន្យ។

ដើម្បីឲ្យពិភពលោកមានភាពស្រស់ថ្លានិងដើម្បីឲ្យពិភពលោកមានសន្តិភាព សូមមនុស្ស

ទាំងឡាយ មេត្តាបដិបត្តិនូវសីលធម៌ឲ្យបានជាប់គ្រប់ពេលវេលា សូមមនុស្សទាំងឡាយ មេត្តានាំគ្នាយកសីលធម៌មកធ្វើជាកល្យាណមិត្ត មានសីលធម៌ក្នុងខ្លួនជានិច្ច កុំបីប្រមាទធ្វេសប្រហែសឡើយ។

សូមពិភពលោកទាំងមូល បានជួបប្រទះតែសេចក្តីសុខនិងសន្តិភាព សូមឲ្យសីលធម៌បានជ្រួតជ្រាប ក្នុងខ្លួនមនុស្សគ្រប់ៗគ្នា សូមកុំឲ្យមានការបៀតបៀនកាប់សម្លាប់ជីវិតមនុស្សសត្វឡើយ សូមឲ្យអត្ថបទមួយនេះ បានជាជំនួយដល់សតិស្មារតីក្នុងការប្រតិបត្តិសីលធម៌របស់មនុស្សក្នុងលោក សូមឲ្យមនុស្សលោកបានរួចចាកពីភយន្តរាយ សូមឲ្យចៀសឆ្ងាយពីក្តីទុក្ខសោកពីពេលនេះតទៅហោង។

## សហគមន៍ខ្មោចនិងទេវតា

សហគមន៍ គឺការរស់នៅរួមគ្នា ធ្វើការរួមគ្នា ការរស់នៅជាក្រុមគ្រួសារធ្វើការរួមគ្នា ដំណើរទៅជាមួយគ្នា ការប្រមូលផ្តុំគ្រួសារច្រើនឲ្យចូលមករស់នៅរួមគ្នា ហើយធ្វើការរួមគ្នា យ៉ាងនេះហៅថាសហគមន៍។

ការរស់នៅក្នុងសហគមន៍ជាមួយគ្នាយើង មិនអាចគេចផុត ពីការជួបជាមួយនឹងមនុស្សអាក្រក់ និងមនុស្សល្អបានឡើយ។ ទោះបីការរស់នៅនោះក្នុងសហគមន៍តូចរស់នៅជាក្រុមគ្រួសារយ៉ាងណាក៏ដោយ គង់តែមានមនុស្សអាក្រក់និងមនុស្សល្អ រស់នៅជាមួយមិនខាន។

មនុស្សអាក្រក់ ក្នុងព្រះពុទ្ធសាសនា ព្រះ-អង្គទ្រង់សម្តែងថា[១] ជាមនុស្សដែលជាអ្នកធ្វើ

---

១ បិដកលេខ៤២ ទំព័រ១៤១

នូវបាណាតិបាត ធ្វើនូវអទិន្នាទាន ប្រព្រឹត្តនូវកាមេសុមិច្ឆាចារ ពោលពាក្យមុសា ក្រេបផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេចពួកសមណព្រាហ្មណ៍។ មនុស្សដែលប្រព្រឹត្តធម៌យ៉ាងនេះ លោកឲ្យឈ្មោះថា ជាមនុស្សអាក្រក់ ឬខ្មោច។

មនុស្សល្អ ក្នុងព្រះពុទ្ធសាសនាព្រះអង្គទ្រង់សម្តែងថា[១] ជាមនុស្សដែលជាអ្នក វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកការ

១ បិដកលេខ៤២ ទំព័រ១៤២

ក្រេបផឹកនូវទឹកស្រវឹង គឺសុរានិង មេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ជាអ្នកមានសីលមានធម៌ល្អ មានចិត្តប្រាសចាកមន្ទិលគឺសេចក្ដីកំណាញ់ នៅគ្រប់គ្រងផ្ទះ ជាអ្នកមិនជេរប្រទេចពួកសមណព្រាហ្មណ៍។ មនុស្សដែលប្រព្រឹត្តធម៌យ៉ាងនេះ លោកឲ្យឈ្មោះថា ជាមនុស្សល្អឬទេវតា។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់សម្ដែងទៀតថា[១] ជនទាំងពីរនាក់[២] ជាអ្នកទ្រុស្តសីល ជាអ្នកកំណាញ់ស្វិតស្វាញ ជេរប្រទេច(នូវសមណព្រាហ្មណ៍) ប្រពន្ធនិងប្ដីទាំងពីរនាក់នោះ ឈ្មោះថាខ្មោចមកនៅរួមគ្នា។ ស្វាមីជាអ្នកទ្រុស្តសីល មានសេចក្ដីកំណាញ់ស្វិតស្វាញ ជេរប្រទេច(នូវ

១ បិដកលេខ៤២ ទំព័រ១៨៤, ២ ប្ដីនិងប្រពន្ធ

សមណព្រាហ្មណ៍) ភរិយាជាអ្នកមានសីល ដឹងនូវពាក្យពេចន៍នៃពួកស្មូម មានសេចក្តីកំណាញ់ប្រាសចាកហើយ ភរិយានោះឯងឈ្មោះថា ទេវតាស្រី នៅរួមគ្នាជាមួយនឹងប្តីខ្មោច។ ស្វាមីជាអ្នកមានសីល ដឹងនូវពាក្យពេចន៍នៃពួកស្មូម ជាអ្នកមានសេចក្តីកំណាញ់ប្រាសចាកហើយ

ភរិយាជាអ្នកទ្រុស្តសីល មានសេចក្តីកំណាញ់ ស្និតស្នាញ ជេរប្រទេច(នូវសមណព្រាហ្មណ៍) ភរិយានោះឯងឈ្មោះថា ខ្មោចស្រីនៅរួមគ្នាជាមួយនឹងប្តីទេវតា។ ជនទាំងពីរនាក់ ជាអ្នកមានសទ្ធាដឹងនូវពាក្យពេចន៍នៃពួកស្មូម ជាអ្នកសង្រួម (ក្នុងសីល) ជាអ្នកចិញ្ចឹមជីវិតតាមគន្លងធម៌ ប្រពន្ធនិងប្តីទាំងពីរនាក់នោះ ពោលពាក្យផ្អែមល្ហែមទៅរកគ្នានឹងគ្នា រមែងមានសេចក្តីចម្រើនដ៏

ច្រើន ទាំងមានការនៅជាសុខកើតឡើងដល់គ្នានិងគ្នា ពួកសត្រូវ រមែងអាក់អន់ចិត្ត ចំពោះជនទាំងពីរនាក់ ដែលមានសីលស្មើគ្នា ជនទាំងពីរនាក់ មានសីលនិងវត្តស្មើគ្នា ក៏រមែងជាអ្នកត្រេកអរ រីករាយ ក្នុងទេវលោកបាន។

អំពិលផ្អូរសាច់ ដុះចេញពីអាចម៍ បែបរាងសំបើម
លាស់ខ្ពស់ធំទៅ មែកស្លឹកល្អផ្អើម ផ្លែចេញពីដើម
រសផ្អូរដល់ចាស់។
បើយកទៅថ្វៃ ផ្លែអំពិលខ្ចី ឲ្យរសប្តូរផ្លាស់
បានត្រឹមហូបលេង កំដរពេលខ្លះ បើហូបរឹតណាស់
រាករុះរឹងរៃ៕

**សុខ ធម្មតាសី**

## អ្នកធំ

ស្ទើរតែគ្រប់មនុស្សទាំងអស់ទៅហើយ នៅពេលដែលបានឮពាក្យថាអ្នកធំ ពួកគេច្រើនតែនាំគ្នាគិតទៅដល់អ្នកគ្រប់គ្រងប្រទេស គិតដល់ព្រះរាជា នាយករដ្ឋមន្ត្រី ឬគិតដល់ប្រធានរបស់ខ្លួន។ តែពួកគេមិនសូវគិតដល់ខ្លួនឯងទេ តាមពិតទៅអ្នកធំពិតជាអ្នកនោះ យើងនៅមិនទាន់បានដឹងនៅឡើយទេ។

ដើម្បីបានដឹងច្បាស់ ក្នុងរឿងអ្នកធំនេះ សូមអ្នកអានទាំងឡាយ មេត្តាអាននូវអត្ថបទមួយ ដែលសរសេរដោយសម្តេចព្រះមហាឃោសនន្ទ ដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ក្នុងបឋមកប្បនេះ ទេវបុត្រ និងទេវតាទាំងឡាយ បានបើកមហាសន្និបាតមួយ ដើម្បី

បោះឆ្នោតជ្រើសរើសរកអ្នកដែលមានសមត្ថភាព សមរម្យគ្រប់គ្រាន់ ដើម្បីឲ្យគ្រប់គ្រងចក្រវាល។ បេក្ខជនដំបូងគឺ **ព្រះអគ្គីទេវបុត្រ** (ទេវតាភ្លើង) ព្រះអង្គមានព្រះបន្ទូលថា ខ្ញុំជាអ្នកមានអានុភាពខ្លាំងបំផុត ដូច្នេះខ្ញុំមានអានុភាពអាចគ្រប់គ្រងចក្រវាលនេះបាន អស់លោកបានឃើញឥទ្ធិពលរបស់ខ្ញុំស្រាប់ហើយតើ រួចហើយព្រះអង្គបានសម្តែងឫទ្ធិក្នុងសម្លេងដ៏ខ្លាំងៗ អណ្តាតភ្លើងដ៏ធំសម្បើម បានតាំងឡើងពីមណ្ឌលចក្រវាល ហើយបានឆាបឆេះសន្ធោសន្ធៅគ្រប់ទីកន្លែង។ ទេវតាទាំងអស់មានការភ័យតក់ស្លុតតក្កមា ហើយបានលើកហត្ថាឡើងជាសញ្ញា យល់ព្រមបោះឆ្នោតជ្រើសរើស **អគ្គីទេវបុត្រ** ឲ្យឡើងគ្រប់គ្រងចក្រវាល លើកលែងតែ **វលាហកទេវបុត្រ**ចេញ

(ទេវតាខាងទឹក) **វលាហកទេវបុត្រ** បានប្រកាសថា"ខ្ញុំមានកម្លាំងអាចគ្រួតត្រាលើភ្លើងបាន" ពេលនោះស្រាប់តែព្រះអង្គបង្កើត ទឹកជំនន់ដ៏សម្បើមមួយដើម្បីរំលត់ភ្លើង។ ទឹកជំនន់បានជន់ឡើងខ្ពស់។ ទេវតាទាំងអស់បានលើកហត្ថាឡើង ជាសញ្ញាយល់ព្រមឲ្យតំណែងនេះទៅ **វលាហកទេវបុត្រ**។ លើកលែងតែព្រះនាង **សារទទេវី**(ទេវតាខាងសិល្បៈនិងបញ្ញា)។

ព្រះនាង **សារទទេវី** មានព្រះសវនីយ៍ឡើងថា "ប្រិយមិត្តទាំងអស់ជាទីស្នេហា! ភ្លើងហើយនិងទឹកច្បាំងគ្នាធ្វើឲ្យប្រជាជនស្លាប់រង្គាលចំណែកខ្ញុំវិញ ជាអ្នកបង្កើតនូវសម្ផស្សដ៏ស្រស់គួរជាទីត្រេកត្រអាល។ នៅពេលខ្ញុំចាប់ផ្តើមរាំម្តងៗ អ្នកទាំងឡាយនឹងបានបន្ទូរអារម្មណ៍ការព្រួយ

គ្រប់យ៉ាង។ ចូរបំភ្លេចទឹក និងភ្លើងចោលទៅ"។ រួចហើយព្រះនាងរាំក្នុងកាយវិការទន់ល្វន់ និងច្រៀងយ៉ាងពីរោះ។ ទេវតាទាំងអស់ហាក់ដូចជាភ័ន្តភាំងស្មារតី ជំនួសការសោយទឹកតាមព្រះឱស្ឋទេវបុត្រ ទេវធីតាទាំងអស់នោះ បានយកស្រាទៅចាក់ក្នុងព្រះកណ្ណខ្លះ ក្នុងព្រះនេត្រខ្លះ ក្នុងព្រះនាសាខ្លះ ហើយនាំគ្នាសរសើរអំណាចព្រះនាង **សារទទេវី** រួចលើកហត្ថាឡើងថា ត្រូវតែប្រគល់នាទី គ្រប់គ្រងចក្រវាលឲ្យទៅព្រះនាង **សារទទេវី**។ ពេលនោះ**គន្ធព្វទេវបុត្រ** (ទេវតាខាងតន្ត្រីទិព្វ) ក្រោកឈរឡើងជាសញ្ញាមិនយល់ព្រម។

ព្រះអង្គមានព្រះបន្ទូលថា "ស្ត្រីខ្លាំងជាងបុរសឬ តាមពិតបុរសក៏អាចយកឈ្នះលើស្ត្រីបានដែរ"។ ព្រះអង្គចាប់ចាប៉ីមកដេញក្នុងសម្លេង

ទិព្វសែនពីរោះក្រៃលែង ហើយច្រៀងផង។ ទេវតាទាំងអស់ភ័ន្តភាំងស្មារតីនឹងសំឡេងតន្ត្រី ដែលលាន់រងំក្នុងសាលប្រជុំដោយអាការៈវង្វេងស្មារតី។ អង្គប្រជុំបានលើកហត្ថាឡើងព្រមៗគ្នា ជាសញ្ញាថា នាទីគ្រប់គ្រងចក្រវាល ត្រូវតែបានទៅលើ **គន្ធព្វទេវបុត្រ។** ខណៈនោះ **សន្តិទេវ-បុត្រ**(ទេវតាខាងសន្តិភាព"សតិសម្បជញ្ញៈ") មានព្រះបន្ទូលឡើងយ៉ាងស្ងប់ស្ងាត់ថា "ខ្ញុំជាទេវបុត្រខាង **សន្តិភាព** ខ្ញុំតែងតែប្រតិបត្តិនូវសតិសម្បជញ្ញៈ ទោះជាអ្នកទាំងឡាយបោះឆ្នោតឲ្យខ្ញុំក្ដី មិនបោះឲ្យក្ដី ក៏ខ្ញុំអាចគ្រប់គ្រងខ្លួនរបស់ខ្ញុំបានដែរ។ ដើម្បីគ្រប់គ្រងចក្រវាល មុនដំបូងអ្នកត្រូវគ្រប់គ្រងខ្លួនអ្នកសិន ដើម្បីគ្រប់គ្រងខ្លួនអ្នក អ្នកត្រូវគ្រប់គ្រងចិត្តរបស់អ្នកសិន ដើម្បី

គ្រប់គ្រងចិត្តរបស់អ្នក អ្នកត្រូវប្រតិបត្តិតាម សតិ និងសម្បជញ្ញៈ។

ទេវសន្និបាត បានទទួលស្គាល់ពលានុភាពរបស់**សន្តិទេវបុត្រ**។ ទាំងអស់អង្គបានទំលាក់សន្លឹកឆ្នោត ចូលក្នុងហិបរបស់**សន្តិទេវបុត្រ** ក្នុងគំនិតជាឯកច្ឆន្ទ សូមឲ្យព្រះអង្គឡើងគ្រប់គ្រងចក្រវាលនេះ ព្រោះគ្រប់ៗព្រះអង្គយល់ថា **សន្តិ-ភាព** គឺជាកម្លាំងដ៏រឹងមាំ និងជាកម្លាំងដ៏ខ្លាំងក្លាបំផុតក្នុងលោកនេះ។

ពេលដែលអ្នកអានទាំងឡាយបានអានអត្ថបទនេះ បានដឹងពីរឿងទេវតាទាំងឡាយប្រកួតប្រជែងដណ្តើមគ្នាធ្វើអ្នកធំ ប្រហែលជាអ្នកអានទាំងឡាយនាំគ្នាគិតថា អ្នកធំ គឺជាអ្នកណាម្នាក់ហើយមើលទៅ តាមពិតទៅ អ្នកធំពិត

នោះ មិនមែនជាអ្នកណាក្រៅពីខ្លួនអ្នកហ្នឹងទេ។

ខ្លួនអ្នកគឺជាអ្នកធំជាងអ្នកណាៗទាំងអស់ បើអ្នកមិនអាចគ្រប់គ្រងលើខ្លួនឯងបានទេ តើអ្នកសង្ឃឹមអ្វីទៅលើអ្នកដទៃ ដែលឲ្យមកគ្រប់គ្រងលើខ្លួនអ្នកបាននោះ។

បើចង់ទៅគ្រប់គ្រងអ្នកដទៃ អ្នកត្រូវតែរៀនគ្រប់គ្រងខ្លួនអ្នកឲ្យបានល្អសិន។ ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់សម្តែងថា "បើបុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឯងឲ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនបានល្អហើយ ទើបគួរទៅទូន្មានអ្នកដទៃបាន ព្រោះថាខ្លួនហ្នឹងឯង គឺជាបុគ្គលដែលទូន្មានបានដោយលំបាក"។ នៅក្នុងគាថានេះ ព្រះសម្មាសម្ពុទ្ធព្រះអង្គចង់បញ្ជាក់ថា គ្មានអ្នកណាធំជាងខ្លួន

យើងនេះទេ ព្រោះនៅក្នុងគាថានេះ ព្រះអង្គបានបញ្ជាក់ថា "ខ្លួនហ្នឹងឯង គឺជាបុគ្គលដែលទូន្មានបានដោយលំបាក" ប្រសិនបើខ្លួនយើង ជាបុគ្គលដែលទូន្មានបានដោយលំបាកហើយនោះ តើយើងទៅរកអ្នកណាដើម្បីមកទូន្មានខ្លួនយើង? យើងទៅរកព្រះពុទ្ធឬទៅរកព្រះព្រហ្ម? យើងមិនបាច់ទៅរកអ្នកណាទេ ព្រោះខ្លួនយើងនេះធំជាងអ្នកណាៗទាំងអស់ គឺមានតែខ្លួនយើងទេ ទើបអាចទូន្មានខ្លួនយើងបាន នៅក្នុងខ្លួនមានចិត្តជាអ្នកប្រកបតាក់តែង បើយើងអប់រំចិត្តបានល្អហើយ ខ្លួនយើងច្បាស់ជាក្លាយទៅជាអ្នកធំយ៉ាងពិតប្រាកដ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់សម្តែងថា "អ្វីៗទាំងឡាយគឺសម្រេចមកពីចិត្ត បុគ្គលមានចិត្តជាធំ មានចិត្តប្រសើរបំផុត បើបុគ្គលមាន

ចិត្តត្រូវទោសៈប្រទូសរ៉ាយហើយ ទោះជានិយាយក្តី ធ្វើក្តី ក៏សុទ្ធតែអាក្រក់ទាំងអស់ បុគ្គលបើគ្រប់គ្រងចិត្តបានល្អហើយ ចិត្តជ្រះថ្លាហើយ ទោះជានិយាយក្តី ធ្វើក្តី គឺសុទ្ធតែល្អទាំងអស់ ព្រោះចិត្តដែលជ្រះថ្លានោះឯង សេចក្តីសុខរមែងជាប់តាមបុគ្គលនោះ ដូចជាស្រមោលដែលអន្ទោលទៅតាមប្រាណ យ៉ាងដូច្នោះឯង"។

ជាមួយគ្នានេះដែរ ប្រសិនបើមនុស្សគ្រប់គ្នា អាចយកឈ្នះលើខ្លួនឯងបាន ពិភពលោកនេះ ច្បាស់ជាគ្មានអំពើហិង្សាកើតឡើងឡើយ។

អំពើហិង្សាកើតចេញតែពីមនុស្សដែលមិនចេះយកឈ្នះលើចិត្តខ្លួនឯង គឺមិនចេះយកឈ្នះចិត្តដែលខឹងក្រោធរបស់ខ្លួន ទើបបណ្តាលឲ្យកំហឹងទាំងនោះវាកើតឡើងបាន តែបើយើងចេះ

យកឈ្នះលើចិត្តខ្លួនឯងបាន ប្រឹងទប់ទល់កុំឲ្យសេចក្តីក្រោធកើតឡើង នុ៎ះក្នុងសង្គមនីមួយៗច្បាស់ជាគ្មានអំពើហិង្សាកើតឡើងឡើយ។

ព្រះសម្មាសម្ពុទ្ធព្រះអង្គបានសម្តែងទៀតថា បុគ្គលណា ដែលឈ្នះមនុស្ស១លាននាក់នៅក្នុងសមរភូមិ បុគ្គលនោះមិនឈ្មោះថាជាអ្នកឈ្នះដ៏ប្រសើរទេ ចំណែកឯបុគ្គលណា ដែលយកឈ្នះលើខ្លួនឯងតែម្នាក់បាន បុគ្គលនោះគឺជាអ្នកដែលឈ្នះដ៏ប្រសើរបំផុត ក្នុងសមរភូមិ។

បើចង់គ្រប់គ្រងចក្រវាល អ្នកត្រូវតែគ្រប់-គ្រងខ្លួនរបស់អ្នកឲ្យបានសិន បើចង់គ្រប់គ្រងខ្លួនរបស់អ្នក អ្នកត្រូវតែគ្រប់គ្រងចិត្តរបស់អ្នក បើអ្នកចង់គ្រប់គ្រងចិត្តរបស់អ្នក អ្នកត្រូវតែមានសតិនិងសម្បជញ្ញៈឲ្យបានល្អខ្ជាប់ខ្ជួនជានិច្ច។

អ្នកធំ គឺមនុស្សដែលមានសតិសម្បជញ្ញៈល្អ ចេះគ្រប់គ្រងចិត្តមិនឲ្យខឹងក្រោធ ជាមនុស្សដែលមានមេត្តារវាងគ្នានិងគ្នា និងជាមនុស្សដែលមិនវង្វេងវង្វាន់ស្មារតី។

ផ្លែធ្វើមុខពីរ ចង់ស៊ីសាច់ក្រៀម
ទន្សាយនៅស្ងៀមស្វាឃើញចំអក
ភេឈ្លោះទាស់គ្នា ឲ្យក្ដីចចក
ក្ដីភេខូចខក ចចកបានផល។
**សុខ ធម្មភាសី**

## លេខ១និងលេខ២

មានសំណួរមួយគេសួរថា **លេខ១និង លេខ២** តើលេខមួយណាដែលល្អជាងគេ?

មនុស្សជាច្រើនបានឆ្លើយថា លេខ១គឺជាលេខដែលល្អជាងគេ។

សំណួរមួយទៀតបានសួរថា ហេតុអ្វីបានជាអ្នកហ៊ានឆ្លើយថាលេខ១គឺជាលេខ ដែលល្អជាងគេ?

មនុស្សជាច្រើនដដែលនោះបានឆ្លើយទៀតថា លេខ១គឺជាចំណាត់ថ្នាក់ដែលល្អដាច់គេ អ្នកណាៗក៏ចង់បានលេខ១ដែរ។

តែជាមួយគ្នានោះ អ្នកវិភាគបែបគណិត-វិទ្យាបែរជាមិនយល់ស្រប ហើយបានឆ្លើយទៅ

វិញថា លេខ១សម្រួលមិនកើតទេ មានតែលេខ២ទេទើបអាចសម្រួលកើត ហេតុនេះលេខ១មិនល្អទេ លេខ២ទើបល្អជាង។

ហេតុអ្វីបានជាបញ្ច្រាសគ្នាយ៉ាងនេះទៅវិញ? ចុះអ្នកអានទាំងឡាយយល់ថាយ៉ាងម៉េចដែរ? តើលេខ១ល្អ? ឬលេខ២ល្អ?

មានការជជែកវែកញែកគ្នាជាយូរណាស់មកហើយ ពីរឿងលេខ១ល្អនិងលេខ២ល្អនេះ ដែលការជជែកវែកញែកគ្នានោះ មានមនុស្សជាច្រើនបានអះអាងថា លេខ១គឺជាលេខដែលល្អជាងគេដោយពួកគេបានពឹងផ្អែកទៅលើចំណាត់ថ្នាក់លេខ១ ហើយពួកគេបានលើកយករឿងដែលកើតពិតៗ មកធ្វើជាអំណះអំណាងថា កាលបើមានអ្នកណាម្នាក់ដែលរៀនពូកែជាងគេនៅក្នុង

ថ្នាក់ អ្នកនោះនឹងទទួលបាននូវចំណាត់ថ្នាក់លេខ១យ៉ាងពិតប្រាកដ។

កីឡាករប្រដាល់វាយបុក កាលបើវាយបានខ្លាំង វាយចំលើគូប្រកួតបានច្រើន ចៅក្រមនិងអាជ្ញាកណ្តាលច្បាស់ជាប្រគល់នូវជ័យលាភីលេខ១នេះ ឲ្យទៅកីឡាករនោះជាមិនខាន។

ក្រុមកីឡាករបាល់ទាត់ កាលបើទាត់បាល់ឲ្យចូលទៅក្នុងទីខាងក្រុមម្ខាងទៀត បានចំនួនច្រើនជាង ក្រុមកីឡាករនោះក៏ទទួលបាននូវជយលាភីលេខ១នេះដែរ...។

ហេតុនេះហើយបានជាមានមតិមនុស្សជាច្រើនហ៊ានអះអាងថា លេខ១គឺជាលេខដែលល្អជាងគេ។

បើយើងមើលទៅលើអំណះអំណាងខាង

លើនេះវាជាការពិតណាស់ ដែលមនុស្សទាំង-ឡាយនាំគ្នានិយាយថា លេខ១គឺជាលេខដែលល្អជាងគេនោះ។

តែបើយើងវិភាគបែបគណិតវិទ្យាវិញ យើងនឹងបានឃើញថា លេខ១មិនមែនជាលេខល្អទេ ព្រោះលេខ១សម្រួលមិនកើត លេខដែលល្អគឺលេខ២ទៅវិញទេ លេខ២ទើបសម្រួលកើត។

នៅពេលដែលមានទស្សនៈ វិភាគបែបគណិតវិទ្យានេះកើតឡើង មនុស្សទាំងឡាយនាំគ្នាពោលទៅកាន់អ្នកបញ្ចេញទស្សនៈនេះថា ជាមនុស្សឆ្កួតខុសគេខុសឯង ហើយមនុស្សទាំង-ឡាយបាននាំគ្នាពោលថា គេនិយាយពីចំណាត់ថ្នាក់លេខ១ ដែលមនុស្សទាំងឡាយនាំគ្នាប្រឹង

ប្រកួតប្រជែងគ្រប់កាលៈទេសៈ ដើម្បីដណ្តើមយកឲ្យ បាននូវជ័យលាភីលេខ១នេះ តែបែរជាមានអ្នកមកបញ្ចេញនូវទស្សនៈ វិភាគបែបគណិតវិទ្យាឆ្លុតៗទៅវិញ។ រឿងសម្រួលកើតមិនកើតវាជារឿងរបស់គណិតវិទ្យា រីឯរឿងប្រកួតប្រជែងអ្នកណាៗក៏គេចង់បានលេខ១ដែរ។

នៅលើសកលលោកយើងនេះ បើមានអ្នកណាដែលលេចធ្លោជាងគេ មានជំនាញជាងគេផ្នែកខាងធ្វើអ្វីមួយនុ៎ះ អ្នកនោះឯងនឹងក្លាយជាមនុស្សលេខ១នៅក្នុងលោក។ មនុស្សដែលជាប់ចំណាត់ថ្នាក់លេខ១ គឺជាមនុស្សដែលប្រសើរនិងល្អជាង គេនៅក្នុងលោក។

ដូចជាអ្នកប្រាជ្ញម្នាក់នៅក្នុងប្រទេសអ៊ីតាលីលោក **ហ្គាលីអូ ហ្គាលីលេ** ជាអ្នក ដឹងថាផែនដី

មានរាងមូលនិងធ្វើចលនាវិលជុំវិញខ្លួនឯង មនុស្សទាំងឡាយបានសរសើរ និងលើកដំកើងគាត់គ្រប់ៗគ្នា។

ហេតុនេះហើយបានជាយើងខ្ញុំទាំងអស់គ្នាយល់ឃើញថា លេខ១គឺត្រូវតែល្អជាងលេខ២។

ចំណែកទស្សនៈបែបគណិតវិទ្យាវិញ បានពន្យល់ទៅកាន់អ្នកលេខ១និយមថា ទោះជាវិភាគទៅជាបែបណាក៏ដោយ ក៏លេខ២នៅតែល្អជាងលេខ១ដែរ។

បើយើងនិយាយពីការឈ្នះចាញ់វិញ លេខ២គឺឈ្នះលេខ១ដាច់ទាំងស្រុង ព្រោះលេខ២គឺចំនួនពីរ រីឯលេខ១វិញជាចំនួនតែមួយប៉ុណ្ណោះ។

បើយើងនិយាយអំពីរឿងហានន្តរសេក្តិ អ្នក

មានសក្តិ១ត្រូវតែនៅក្រោមបង្គាប់បញ្ជាអ្នកមានសក្តិ២ជាដរាប។ បើមនុស្សទាំងឡាយនៅតែនិយាយថា អ្នកមានចំណាត់ថ្នាក់លេខ១ គឺជាមនុស្សដែលប្រសើរជាងគេនុ៎ះ គឺមិនទាន់ត្រឹមត្រូវទេ។

នៅលើពិភពលោកយើងនេះ អ្នកដែលមានចំណាត់ថ្នាក់លេខ១មានច្រើនណាស់ ប៉ុន្តែចំណាត់ថ្នាក់លេខ១មិនប្រាកដថា នៅជាប់ជាមួយហ្នឹងអ្នកនោះរហូតទេ។ បុរាណលោកពោលថា ភ្នំមួយខ្ពស់ គង់មានភ្នំមួយខ្ពស់ជាងទៀត។ លោក ហ្គាលីអូ ហ្គាលីលេ ជាតារាវិទូនៅក្នុងប្រទេសអ៊ីតាលី ជាអ្នកបានដឹងថាផែនដីមានរាងមូល ធ្វើចលនាវិលជុំវិញខ្លួនឯង តែក្រោយមកអ្នកប្រាជ្ញជំនាន់ថ្មីគេដឹងច្រើនជាងគាត់ទៅទៀត។

អ្នកប្រាជ្ញនៅក្នុងប្រទេសអង់គ្លេស លោក អ៊ីសាក ញ៉ូតុន គាត់បានដឹងពីមូលហេតុដែលព្រះចន្ទនិងព្រះអាទិត្យមិនធ្លាក់មកក្រោម ដោយសារតែមានទំនាញផែនដី។ អ្នកប្រាជ្ញជាច្រើនទៀតនៅលើពិភពលោក ក្រោយមកគេបានដឹងថា នៅលើពិភពលោកយើងនេះ ក្រៅពីភពផែនដីគឺនៅមានភពជាច្រើនទៀតដែលគេបានរកឃើញ អ្នកប្រាជ្ញរបស់ប្រទេសអាមេរិក បានឡើងទៅដល់ភពព្រះចន្ទតែក៏មិនប្រាកដថា មានតែអ្នកប្រាជ្ញរបស់ប្រទេសអាមេរិកតែមួយនោះទេ គឺនៅមានអ្នកប្រាជ្ញជាច្រើនទៀតដែលគេអាចឡើងទៅដល់ភពព្រះចន្ទ។

ប្រសិនបើជាយ៉ាងនេះមែន តើអ្នកណាជាអ្នកលេខ១? មើលទៅលើចំណាត់ថ្នាក់លេខ១

គឺមានច្រើនណាស់សម្រួលមិនកើតទេ។

ជាងនោះទៅទៀត នៅក្នុងប្រទេសចិនក្នុងទីក្រុងសៀងហៃ មានផ្លូវមួយឈ្មោះថាផ្លូវឆាងអាន ជាកន្លែងលក់កាំបិតនិងដាវល្បីជាងគេ គ្រប់ហាងដែលលក់កាំបិតនិងដាវទាំងនោះ មួយណាក៏គេសរសេរថាលេខ១ដែរ តើកាំបិតនិងដាវទាំងអស់នោះ សុទ្ធតែលេខ១ទាំងអស់មែនឬ?

ដូចគ្នានេះដែរ សេវាកម្មទូរសព្ទគ្រប់ប្រព័ន្ធទាំងអស់ សុទ្ធតែធ្វើការប្រកាសផ្សព្វផ្សាយថាមានសេវាគ្រប់ទីកន្លែងល្អលេខ១ទាំងអស់ តើសេវាកម្មទូរសព្ទទាំងអស់ ពិតជាលេខ១ទាំងអស់មែនឬ? រឿងនេះសូមឲ្យអ្នកលេខ១និយមវិភាគដោយខ្លួនឯងចុះ។

មួយវិញទៀត បើយើងនៅតែនាំគ្នានិយាយ

ថា  អ្នកដែលមានចំណាត់ថ្នាក់លេខ១នៅតែល្អប្រសើរនោះ ទស្សនៈវិភាគបែបគណិតវិទ្យាយើងខ្ញុំ សូមលើកយកបុគ្គល ដែលមានចំណាត់ថ្នាក់លេខ១ដើម្បីយកមកបញ្ជាក់ឲ្យបានច្បាស់។

លោក **បេនីតូ មូសូលីនី** ជាអ្នកដឹកនាំខ្លាំងជាងគេនៅក្នុងប្រទេសអ៊ីតាលី ប្រជាជនអ៊ីតាលីបានហៅគាត់ជាភាសាអ៊ីតាលីថា **អ៊ីល ឌូឆេ** មានន័យថា **អ្នកដឹកនាំលេខ១ ឬអ្នកដឹកនាំឯក** ដែលបានដឹកនាំប្រជាជនអ៊ីតាលីអស់រយៈពេល ២៣ឆ្នាំ។ គាត់ជាអ្នកដែលធ្វើឲ្យប្រជាជនអ៊ីតាលីស្លាប់ច្រើនជាងគេ។

នៅទីបញ្ចប់ **មូសូលីនី** ត្រូវបានកងទ័ពដឹកយកទៅបាញ់ចោលនៅទីកន្លែងស្ងាត់មួយ ហើយយកខ្មោចរបស់គាត់មកឲ្យប្រជាជនទាត់ធាក់គប់

ត្រវែង និងលើកខ្មោចគាត់ចងជើងឡើងលើទុកចោលដើម្បីរម្សាយនូវកំហឹងរបស់ប្រជាជនទៅ-វិញ។

ដូចគ្នានេះដែរ **អាដុលហ្វ៍ ហ៊ីត្លែរ** ក៏ជាអ្នកខ្លាំងម្នាក់ នៅក្នុងប្រទេសអាល្លឺម៉ង់ផងដែរ។ ប្រជាជនអាល្លឺម៉ង់បានហៅគាត់ជាភាសាអាល្លឺ-ម៉ង់ថា **ហ៊្វូរឺ** ប្រែថា **អ្នកដឹកនាំ** គាត់បាន ទទួលមេដាយឥស្សរិយយសមួយដែលមានឈ្មោះថា **អៃរ៉ុនក្រស** (ចំណាត់ថ្នាក់លេខ១) សរុបមក **អាដុលហ្វ៍ ហ៊ីត្លែរ** ក៏ជាមនុស្សមានចំណាត់ថ្នាក់លេខ១ដែរ។ **អាដុលហ្វ៍ ហ៊ីត្លែរ** ជាមេដឹកនាំផ្តាច់ការមុនគេនៅក្នុងប្រទេសអាល្លឺម៉ង់និងជាអ្នកធ្វើឲ្យប្រជាជនអាល្លឺម៉ង់ស្លាប់ជាច្រើនផងដែរ។

នៅទីបញ្ចប់ **អាដុលហ្វ៍ ហ៊ីត្លែរ** ត្រូវបាន

កងទ័ពតាមចាប់ខ្លួនយកមកផ្ដន្ទាទោស តែ ហ៊ីត្លែ មិនឲ្យកងទ័ពចាប់គាត់ទេ គាត់បានឲ្យស្រី កំណាន់ចិត្តរបស់គាត់ យកកាំភ្លើងបាញ់បំបែក ក្បាលគាត់ទៅវិញ។

រឿងទាំងអស់ដែលបានលើកមកនៅខាង លើនេះ គ្រាន់តែចង់យកមកបញ្ជាក់ថា អ្នកដែល មានចំណាត់ថ្នាក់លេខ១ គឺមិនមែនសុទ្ធតែល្អ ទាំងអស់នោះទេ។

ទស្សនៈវិភាគបែបគណិតវិទ្យាយើងខ្ញុំចង់ បញ្ជាក់ថា លេខ១ដែលសម្រួលមិនកើតនៅក្នុង សេចក្ដីនេះគឺមានន័យថា **យកតែគំនិតខ្លួនឯង គំនិតគេសុទ្ធតែខុសទាំងអស់ អ្នកណានិយាយអ្វី ក៏មិនត្រូវ ខ្លួនឯងនិយាយអ្វីគឺសុទ្ធតែត្រូវទាំង- អស់។** ហើយលេខ២នៅក្នុងសេចក្ដីនេះមានន័យ

ថា ស្របតាមគំនិតកូនចៅផងគំនិតខ្លួនផង "សេចក្តីទុក្ខរបស់កូនចៅគឺជាសេចក្តីទុក្ខរបស់មេដឹកនាំ"។

យ៉ាងនេះហើយ បានជាទស្សនៈបែបគណិតវិទ្យាយើងខ្ញុំយល់ថា លេខ១សម្រួលមិនកើតទេ លេខ២ទើបសម្រួលកើត ហេតុនេះលេខ១មិនល្អទេលេខ២ទើបល្អ។

បើយើងមើលទៅលើមតិទាំងអស់ខាងលើនេះ គឺសុទ្ធតែជាមតិល្អៗទាំងអស់ ទាំងការអំណះអំណាងដែលលើកយកមកបញ្ជាក់ក៏សុទ្ធតែល្អរៀងៗខ្លួនដែរ តែចំពោះមតិរបស់រចនាករផ្ទាល់វិញបានយល់ឃើញថា លេខ២គឺល្អជាងលេខ១។

បានជារចនាករហ៊ាននិយាយថាលេខ២ ល្អ

ជាងលេខ១ ព្រោះរចនាកររយល់ឃើញថា គំនិត លេខ១គឺជាគំនិតមារនិងគំនិតទេវទត្ត ជាគំនិត ចង់តែឈ្នះតែម្យ៉ាងប៉ុណ្ណោះ។ ឲ្យតែបានឈ្នះ អ្នកណាយ៉ាងម៉េចក៏យ៉ាងម៉េចទៅ គឺមិនខ្វល់អ្វី ទាំងអស់ឲ្យតែខ្លួនឯងបានក្លាយជាអ្នកខ្លាំង។

ដូចកាលពីជាង២៦០០ឆ្នាំមុន ពេលដែល ព្រះសិទ្ធត្ថព្រះអង្គហៀបនឹងត្រាស់ដឹងជាព្រះ សម្មាសម្ពុទ្ធ ស្រាប់តែទេវបុត្រមារដែលមានអំ-ណាចលើពួកទេវតានិងពួកព្រហ្មទាំងឡាយ កើត ចិត្តអាក្រក់ខ្លាចព្រះសិទ្ធត្ថត្រាស់ដឹងនឹងមាន អំណាចជាងខ្លួន មារបាននាំពលសេនារាប់កោដិ នាក់ទៅធ្វើសង្គ្រាមដណ្តើមរតនបល្ល័ង្កពីព្រះអង្គ ដើម្បីមិនឲ្យព្រះអង្គបានត្រាស់ដឹង។ មារមានចិត្ត បាប បានធ្វើនូវព្យុះកំណាច៩យ៉ាង បោកបក់មក

លើព្រះអង្គយ៉ាងខ្លាំងក្លា។

មួយវិញទៀត ពេលដែលព្រះអង្គបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធភិក្ខុទេវទត្តកំណាចបាននាំនូវពួកចោររាប់រយនាក់ឲ្យទៅសម្លាប់ព្រះ-អង្គ និងបានបំបែកសង្ឃឲ្យបែកចេញជាពីរពួកដើម្បីខ្លួនក្លាយទៅជាអ្នកដឹកនាំសង្ឃខ្លាំងជាងព្រះអង្គ។

មិនតែប៉ុណ្ណោះ សូម្បីតែព្រះបាទ **អជាត-សត្តុ** ដែលទៅសេពគប់ជាមួយនឹងភិក្ខុទេវទត្តក៏ត្រូវភិក្ខុទេវទត្តញុះញង់ឲ្យទៅសម្លាប់ព្រះបិតាខ្លួន ដើម្បីបានឡើងធ្វើជាស្ដេច គ្រប់គ្រងផែនដីផងដែរ។

ទាំងអស់នេះបើយើងសង្កេតមើលទៅយើងនឹងបានឃើញថា ព្រោះតែចង់បាននូវ

ចំណាត់ថ្នាក់លេខ១តែម្យ៉ាងប៉ុណ្ណោះ។

មួយវិញទៀត ព្រោះតែមហិច្ឆតារបស់មនុស្សប្រាថ្នាចង់បានចំណាត់ថ្នាក់លេខ១មានច្រើនពេកនៅលើពិភពលោក ពិភពលោកស្ទើរតែវិនាសបាត់បង់កាលពីអំឡុងឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨ សង្គ្រាមលោកលើកទី១បានកើតឡើង ធ្វើឲ្យមនុស្សរាប់លាននាក់ត្រូវបានស្លាប់ក្នុងសង្គ្រាម។

ដូចគ្នានោះដែរ ដោយសារតែមហិច្ឆតាលេខ១នៅមិនទាន់អស់ ពិភពលោកបានវិនាសហិនហោចម្តងទៀតក្នុងឆ្នាំ១៩៣៩ ដល់ឆ្នាំ១៩៤៥។ សង្គ្រាមលោកលើកទី២បានកើតឡើង មនុស្សរាប់លាននាក់នៅលើពិភពលោកបានស្លាប់ម្តងទៀត និងអ្នកដែលនៅសេសសល់

ត្រូវរងជាតិគីមីនុយក្លេអែរ មានខ្លះខ្វាក់ភ្នែក ខ្លះទៀតកើតមហារីកព្យាបាលមិនជាក៏ស្លាប់ទៅថែមទៀត។

ប្រសិនបើចំណាត់ថ្នាក់លេខ១កើតឡើង ធ្វើឲ្យពិភពលោកទៅជាយ៉ាងនេះមែន តើយើងទាំងអស់គ្នានៅតែនាំគ្នានិយាយថាលេខ១គឺជាលេខល្អទៀតឬ? បើតាមយល់ប្រហែលជាមិនល្អទេមើលទៅ។

នៅក្នុងសេចក្តីនេះ រចនាករយល់ឃើញថាលេខ១មិនមែនជាលេខល្អទេលេខ២ទើបល្អ។

លេខ២គឺជាគំនិតរបស់ព្រះសម្មាសម្ពុទ្ធ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមិនដែលចង់ឈ្នះអ្នកណាទេ សូម្បីតែលេខ១ក៏ព្រះអង្គមិនដែលចង់បានដែរ។

នៅពេលដែលព្រះអង្គចេញបួស មារបាន

មកប្រាប់ព្រះអង្គថា នៅតែ៧ថ្ងៃទៀត សម្បត្តិស្តេចចក្រនឹងកើតឡើងដល់ព្រះអង្គ តែព្រះអង្គមិននៅប្រាថ្នាសម្បត្តិស្តេចចក្រនោះទេ។ ពេលមារមកផ្ចាញ់ព្រះអង្គព្រះអង្គមិនបានយកឈ្នះមារទេ ព្រះអង្គបានទូន្មានទៅមារឲ្យលះបង់នូវទិដ្ឋិអាក្រក់នេះចេញ។

ដូចគ្នានេះដែរ ព្រះអង្គក៏មិនដែលយកឈ្នះភិក្ខុទេវទត្តដែរ។ ព្រះអង្គបានទូន្មាន ភិក្ខុទេវទត្តឲ្យលះបង់នូវទិដ្ឋិអាក្រក់នេះចេញដូចមារដែរ។

ជាងនោះទៅទៀត ព្រះអង្គបានសម្តែងធម៌ជាគូនឹងគ្នាថា "មានលាភគូនឹងអត់លាភ មានយសគូនឹងអត់យស សរសើរគូនឹងនិន្ទា ស្រលាញ់គូនឹងស្អប់" នៅក្នុងលោកនេះ ព្រមទាំងទេវលោកគ្មានបុគ្គលណាម្នាក់ដែល ថាគេមិនតិះដៀលទេ

សូម្បីតែតថាគត ក៏គេតិះដៀលដែរ។

វាជាការពិតណាស់ បើយើងមើលទៅលើសេចក្តីនេះយើងនឹងបានឃើញថា សូម្បីតែព្រះ-សម្មាសម្ពុទ្ធក៏គេតិះដៀលដែរ តើរកបុគ្គលឯណាឲ្យប្រសើរជាងព្រះសម្មាសម្ពុទ្ធទៀតនោះ? ប្រសិនបើប្រសើរដូចជាព្រះសម្មាសម្ពុទ្ធនៅតែមានគេតិះដៀល តើឲ្យគេ មិនតិះដៀលយើងដូចម្តេចបានទៅ? បើមនុស្សទាំងអស់នៅតែមានគេតិះដៀល តើយើងអាចនិយាយបានទេថាចំណាត់ថ្នាក់លេខ១ គឺជាចំណាត់ថ្នាក់ដែលល្អជាងគេ?

យោងទៅលើសេចក្តីនេះ រចនាករយល់ថាលេខ១មិនល្អទេ ព្រោះលេខ១នៅតែមានគេតិះ-ដៀលដែរ។ បើយើងយោងទៅលើគំនិតវិភាគ

បែបគណិតវិទ្យាវិញ លេខ១សម្រួលមិនកើត ព្រោះយកតែគំនិតខ្លួនឯង ប្រសិនបើលេខ១យកតែគំនិតខ្លួនឯង នៅតែមានគេតិះដៀលរចនាករ យល់ថា លេខ១មិនល្អទេលេខ២ទើបល្អ។

ហេតុនេះអ្នកដឹកនាំគ្រួសារទាំងឡាយ គួរតែយកលេខ២មកដឹកនាំគ្រួសារ គឺស្របតាមគំនិតកូនចៅផងគំនិតខ្លួនឯងផង សេចក្តីទុក្ខរបស់កូនចៅគឺជាសេចក្តីទុក្ខរបស់មេ គ្រួសារ។ សូមកុំយកគំនិតលេខ១ ដែលជាគំនិតយល់តែពីអារម្មណ៍របស់ខ្លួនឯង មិនយល់ពីអារម្មណ៍របស់អ្នកដទៃ។

# អដ្ឋបើ

បើ វិរិយៈ កុំពាក់សំណាក
បើ ជាចចក កុំត្រាប់ខ្លាត្រី
បើ ភេទជាប្រុស កុំធ្វើជាស្រី
បើ មិនដឹងស្អី កុំស្តីប្រាប់គេ។
បើ ជាអ្នកបួសត្រូវសិក្ខឲ្យហើយ
បើ នៅតោះតើយ គឺមិនល្អទេ
បើ សិក្ខត្រូវឆាប់ កុំនៅរារេ
បើ សិក្ខរកមេ ពិពាហ៍មង្គល។

សិក្ខ=សិក្ខា មានន័យថា សិក្សា **មេ** បាន ដល់អ្នកដឹកនាំ **ពិពាហ៍** មានន័យថា ការនាំទៅ មង្គល មានន័យថា សេចក្តីចម្រើន។

**សុខ ធម្មភាសី**

# បណ្ដាំម៉ែ

១- កូនអើយមកអាយ ចូលមកជិតម្ដាយ
ម្ដាយប្រាប់ណាបា ពីក្ដីស្រលាញ់
និងក្ដីស្នេហា របស់មាតា
លើកូនពីសី។

២- ចូរកូនចងចាំ ពាក្យពេចន៍បណ្ដាំ
ម៉ែផ្ដាំកូនស្រី- ប្រុសក្នុងខេមរា
ជាពាក្យកាព្យថ្មី ចាប់ចួនអត្ថន័យ
សេចក្ដីឲ្យកូន។

៣- ប្រាំបួនខែដប់ថ្ងៃ ដែលម៉ែពរផ្ទៃ
ម៉ែស្ទើរក្ស័យសូន្យ ម៉ែឆ្លងទន្លេ
ឈាមហូរជោកខ្លួន ញើសម៉ែហូរផ្ទួន
ដង្ហើមដង្ហក់។

៤- ម៉ែហូរទឹកភ្នែក ខ្លួនម៉ែស្លាំងស្លេក
កម្លាំងម៉ែអស់ ពេលឃើញមុខកូន
ចិត្តម៉ែស្រណោះ លើកកូនបៅដោះ
ទាំងញ័រជើងដៃ។

៥- ម៉ែហួងហែងខ្លួន តែព្រោះកូនស្ងួន
ម៉ែប្រែហឫទ័យ កាត់កេរ្តិ៍កាត់ខ្មាស
បំបៅថ្នមបី យកឈាមធ្វើក្សីរ
កាយធ្វើបង្គន់។

៦- ទ្រមុតលាមក ភើក្អួតគគ្រក់
ដូចព្រះពិរុណ ដាក់ម៉ែរាល់ថ្ងៃ
ពេញខ្លួនជោរជន់ ម៉ែរងទារុណ
ពីកូនស្រីប្រុស។

៧- ព្រោះក្តីអាណិត ចេញពីទឹកចិត្ត

កូនគ្មានកំហុស ព្រោះកូននៅតូច
ម៉ែចង់ឲ្យរស់ ទោះជាកូនខុស
ក៏ម៉ែមិនថា។

៨- តែម៉ែតូចចិត្ត នឹងឆាកជីវិត
ម៉ែសែនខ្លោចផ្សា ស៊ូចិញ្ចឹមកូន
ឲ្យធំកាយា កូនរឹងសិរសា
មិនស្តាប់ពាក្យម៉ែ។

៩- កូនមិនដឹងគុណ ដើរធ្វើទារុណ
ឥតមានពេលល្ហែ សប្បាយភ្លើតភ្លើន
លក់គេរឱ្យម៉ែ ស៊ីផឹកប៉ោទ្បែ
មិនចូលសាលា។

១០- ឱកូនមាសម្តាយ ម្តេចកូនប្រែក្លាយ
ធ្វើមនុស្សឫស្យា មនុស្សល្អគេរគោក
ម្តេចមិនប្រាថ្នា ឲ្យម៉ែខ្លោចផ្សា

យ៉ាងនេះម្ល៉េះថ្លៃ។

១១- ភ្ជុំបិណ្ឌចូលឆ្នាំ ម៉ែទន្ទឹងចាំ
ផ្លូវកូនប្រុសស្រី សង្ឃឹមកូនជូន
ជំនូនឆ្នាំថ្មី តែកូនអប្រិយ
យកជូនស្រីវា។

១២- ថាណ្តើយកូនប្រុស ឲ្យខុសទៅចុះ
ធ្វើម្តេចវេរា សង្ឃឹមកូនស្រី
ក្រែងបានជាគ្នា ដឹងអីវេទនា
ជាងកូនប្រុសទៀត។

១៣- ឲ្យម្តាយពឹងអ្វី កូនអើយកូនស្រី
បើកូនចោលម្សៀត កែខ្លួនណាកូន
កុំឲ្យខ្មាសញាតិ កែឫកមារយាទ
ធ្វើល្អវិញម្តង។

១៤- ម៉ែចាស់ហើយថ្លៃ មុននឹងម៉ែក្ស័យ
សូមលើកដៃផ្សង សូមកូនប្រុសស្រី
ដើរតាមគន្លង កតញ្ញូម៉ែផង
ណាកូនស្រីណា។

១៥- ផ្តល់ក្តីស្រលាញ់ មកដល់ម៉ែវិញ
ផងណាជីវ៉ា រក្សាពូជពង្ស
វង្សកេរដូនតា មើលថែគ្រួសារ
យើងឲ្យសុខផង។

**សុខ ធម្មាភាសី**

# គ្រួសារបីយ៉ាង

នែ! នាងអំពៅនៅក្នុងចម្ការ

រូបរាងសង្ហាល្អអើយសែនល្អ

ខាងដើមទឹកផ្អែមល្ហែមដូចដាក់ស្ករ

តែចុងវិញហ្ន៎! សាបគ្មានរសជាតិ។

ចំណែកនាងស្ដៅល្វីងអើយសែនល្វីង

ដើមល្វីងស្លឹកល្វីងផ្កាមកល្វីងទៀត

ផ្លែខ្ចីក៏ល្វីងនឹកថាចោលម្សៀត

ដឹងអីប្រែជាតិទំផ្អែមវិញហ្ន៎!។

រីឯនាងឈូកដុះចេញពីភក់

ក្រអៅខ្ចីល្វក់រសឆ្ងាញ់បវរ

ផុសចេញជាផ្កាល្អអើយសែនល្អ

លុះបានផ្លែ-ក៏ឈ្ងុយឆ្ងាញ់ដល់ទុំ។

រុក្ខជាតិទាំងបីប្រៀបបានគ្រួសារ

ដំបូងស្នេហាយូរចោលទ្រនំ
ខ្លះស្អប់គ្នាណាស់ការហើយមនោរម្យ
ខ្លះស្នេហ៍រម្យទមស្រលាញ់ដល់ចាស់។
**សុខ ធម្មតាសី**

បួសបើទុកយូរគឺវាឈើចាប់
រះកាត់ឲ្យឆាប់កុំទុកនាំក្លាយ
បើហ៊ានទុកយូរខ្មុះស៊ីរាងកាយ
ក្រហល់ក្រហាយក្លាយជាពិការ។
**សុខ ធម្មតាសី**

## ស្ងប់ខ្យល់ទឹកមិនរលក

សមុទ្រស្ងប់រលក នៅពេលខ្យល់លែងបក់
ទឹកលែងកករល្អក់ នៅពេលត្រីនៅស្ងៀម
បើមេឃគ្មានពពក រាំងភ្លៀងដីស្ងួតក្រៀម
ប្រទេសកើតសង្គ្រាម ព្រោះចរចាមិនត្រូវ។

**សុខ ធម្មភាសី**

វីសត្វជង្គូវ ពេលវ័យចាស់ទៅ
ក៏ប្តូររូបកាយ ជាមេអំបៅ
ផ្អិនផ្អៅឆើតឆាយ ហិចហើរសប្បាយ
ភ្លេចជាតិអាត្មា។

# អបាយមុខ៤

ឥត្ថីធុត្តោ　　អ្នកលេងឆោឡោ
ល្បែងស្រីពេស្យា ចំណាយធនធាន
ស្រេកឃ្លានកាមា　នៃបនិត្យស្នេហា
ផ្អែមល្ហែមរលួយ ។

សុរាធុត្តោ　　ស្រវឹងបញ្ចោរ
គ្មានគិតភ័យព្រួយ　អ្នកផងដទៃ
គ្រប់វ័យជាមួយ　ធ្លាប់ថៃធ្លាប់ជួយ
ធ្លាប់បីត្រកង ។

អក្ខធុត្តោ　　លេងល្បែងបៀបោរ
ល្បែងភ្នាល់ស៊ីសង លក់ស្រែលក់ស្រូវ
ជូនត្រូវខ្ចីចង-　ការពីអ្នកផង
ព្រោះចង់ស្នងវិញ ។

បាបមិត្តោ　　មិត្តនាំធ្វើចោរ

លួចប្លន់ទំនិញ មាសប្រាក់កែវកង
អ្នកផងបានទិញ ឱ្យគេទោម្នេញ
ឈើចាប់ខ្លោចផ្សា ។
អបាយមុខ ចូរចង់ចាំទុក
មាន៤ប្រការ ដូចបានសម្តែង
ថ្លាថ្លែងកត់ត្រា ខាងលើនេះណា
ហេតុនាំវិនាស ។

**យ៉ា ផូរ**

គីង្គក់កើតស្រែង កុកហើរតែឯង
ក្អែកស្វែងទ្រនំ គង្គក់លក់ថ្នាំ
កុកធ្មេចសំងំ ក្រាបពងខែភ្លំ
ចិកត្រីខែចេត្រ។

## អ្នកជួយឧបត្ថម្ភបោះពុម្ពសៀវភៅ

- ឯកឧត្តម **ឆាន់ សារផាន** និងលោកជំទាវ **គាត កុលណារី** $៤១៥
- លោក **ឈួន ខួនស្រ៊ួយ** និងលោកស្រី **អ៊ុំង ម៉ុយគៀង** ព្រមទាំងបុត្រ $៤១៥
- លោកជំទាវ ឧកញ៉ា **សេង គាង** $១០០
- លោកជំទាវ ឧកញ៉ា **ជៀម ផែន** $១០០
- ឯកឧត្តម **ហ៊ីង គឹមហេង** និងលោកជំទាវ **ស្រី ពៅ** $១០០
- លោកឧកញ៉ា **ស៊ូ ខួន** និង លោកជំទាវ **យឹម ស៊ីថា** $១០០
- លោកជុំទាវឧកញ៉ា **សៀង ចាន់ហេង** នាយកក្រុមហ៊ុន **ហេងអភិវឌ្ឍន៍** $១០០
- លោកជំទាវ **ហូ ណូន** $១០០

- លោកជំទាវ **ចាន់ សុភាព** $១០០
- **Chao Phraya Princess** USA $100
- Mr Ramany & Ms Paulina Yin (RaPaJiKa) USA $100
- លោកស្រី **ចូវ សុលក្ខណ៍** $៥០
- ឯកឧត្តម **អ៊ុក សារុធ** និងលោកជំទាវ **ទ្រី អេង** $៥០
- ឯកឧត្តម **តាន់ គឹមវិន** និងលោកជំទាវ **លីម ឆេង** $៥០
- ឧ.ស. **គ្រៀល ឡើន** ឧ.សិ. **អ៊ុំ សារី**+បុត្រ និងចៅ $២៥
- ព្រះមហា **ឆាត សុឆេត** ១០០.០០០៛
- លោកជំទាវ **ឃឹម ចំរើន** និងស្វាមី ព្រមទាំងបុត្រ ១០០.០០០៛

- ភិក្ខុ កោសលមុនី **បៀវ ថាន** $១០
- ភិក្ខុ ចន្ទធម្មោ **ខៀវ ខន** $១០
- ឧ.សិ. **សោម ឈឿន+ប្រាក់ វិបុល +ប្រាក់ ណាវិ+ប្រាក់ សេថា** ១០$
- លោកស្រី **ចាន់ ផល្លា** និងកូនប្រុស **ចាន់ ធឿនធានិត** ១០$
- លោក **ហាស់ ថុល**(ប៉េ) អ្នកស្រី **លឹម នាង** ព្រមទាំងបុត្រ ៤០.០០០៛
- កញ្ញា ឧ.សិ. **ម៉ៅ វលក្ខ** ៤០.០០០៛
- ឧ.ស. **ចាន់ ប្រាជ្ញ** ឧ.សិ. **សោម អែ** ព្រមទាំងបុត្រនិងចៅ+ចៅទួត ៣០.០០០៛
- លោក **ស៊ុន សារឿន** ឧ.សិ. **ផេង ធី** =២៥.០០០៛
- លោកតា **លឹម ផន** និងបុត្រ ២១.០០០៛

- លោកស្រី **ញ៉ឹម លីមន្ថា**+កូន ២០.០០០៛
- ឯ.ឧ. **ម៉ម ឆៃ** លោកជំទាវ **ជន គា** =២០.០០០៛
- ឧ.ស. **ហាស់ ទូច** ឧ.សិ. **ប៉ុល សារិ** ព្រមទាំងបុត្រ ២០.០០០៛
- លោក **ប៉ាល់ សារ៉ា** លោកស្រី **ហាស់ ស្រី-អូន** ២០.០០០៛
- ឧ.សិ. **ខឹម សុវណ្ណី** ២០.០០០៛
- ឧ.សិ.**មុំម វណ្ណា** ព្រមទាំងបុត្រ ២០.០០០៛
- ឧ.សិ.**ញ៉ឹម លីណាន** ឧ.ស. **មាស សឿន** ព្រងទាំងបុត្រ+ចៅ ២០.០០០៛
- លោក **ច័ន្ទ ឃុតសារី** លោកស្រី **ឈាង សារ៉ា** ព្រមទាំងបុត្រ ២០.០០០៛
- ឧ.សិ.**ខ្លឹង ណាត់** ព្រមទាំងបុត្រ ២០.០០០៛

- លោក **សំ សុត** លោកស្រី **រស់ សាម៉ន** ព្រមទាំងនិងចៅ ២០.០០០៛
- លោក **ឈោ សារឿប** លោកស្រី **ជា ឈួន-ថានី** ព្រមទាំងបុត្រ ២០.០០០៛
- លោក **ជឹម យុន្នី** អ្នកស្រី **ប៉ុល ផល-វណ្ណានី** ព្រមទាំងបុត្រ ២០.០០០៛
- លោក **សេង ឬទ្ធី** លោកស្រី **ឈាង ពេជ្រ-សារ៉ា** ព្រមទាំបុត្រនិងចៅ ២០.០០០៛
- លោក **សៀក គន្ធា** អ្នកស្រី **ហាស់ សារិន** ព្រមទាំងបុត្រនិងចៅ ២០.០០០៛
- លោក **ឡើន សាម្ភួន** អ្នកស្រី **ថោង អួន** ព្រមទាំងបុត្រនិងចៅ ២០.០០០៛
- លោក **ឌេត សំអៀន** និងភរិយា ព្រមទាំងបុត្រ ២០.០០០៛

- លោកតា **ទិន សារ៉េត** និង **ពិន ណៃ** ២០.០០០៛
- លោកស្រី **ចាន់ សុភា** និងស្វាមី+បុត្រ =២០.០០០៛
- លោកតា **ប៉េខ** យាយ **សាខន** ព្រមទាំងកូនចៅ៥$
- ភិក្ខុ **ចាន់ សុធា** ២០.០០០៛
- លោក **អ៊ុន ឈាខ** ឧ.សិ.**ចៅលោកយាយចិនយ៉េខ** និងបុត្រ ២០.០០០៛
- វិជ្ជ. **ទឹម កុសល** លោកស្រី **ញ៉េម រស្មី** $៥
- ឧ.សិ.**ហែម ស៊ីមន**+បុត្រ+ចៅ $៥
- ឧ.សិ. **ហែម ផាន់ណា**+បុត្រ+ចៅ $៥
- លោកយាយ **ហែម សាមិត្ត** ១០.០០០៛
- លោកយាយ **យ៉េម** និងចៅ **រ៉ា** ២០.០០០៛

- ឧ.ស.**គង់ វ៉េង** ឧ.សិ.**ព្រុំ ស៊ាត** ២០.០០០៛
- **ស្រាយ នាង** និង បុត្រ ១៥.០០០៛
- លោកយាយ **ចោង ម៉េត** ហៅម៉ាត់ ព្រមទាំង
  កូនចៅ ១៥.០០០៛
- **យាយ អុន** ១៥.០០០៛
- អ្នកស្រី **សេក ថុល**+ស្វាមី+បុត្រ ១៤.០០០៛
- ឧ.សិ. **ហ៊ី យឿន** និងកូន+ចៅ ១២.០០០៛
- ឧ.សិ. **ទេន ហុន**=១០.០០០៛
- ឧ.សិ.**ពា អេងស៊ីម** +បុត្រ+ចៅ ១២.០០០៛
- ឧ.សិ. **ហែន សារ៉ាវី** ១២.០០០៛
- **ទាញ ហឿន** ១០.០០០៛
- ឧ.សិ.**តឹក សុខគេង** ព្រមទាំងកូន ១០.០០០៛
- ឧ.សិ. **ហ៊ឹម ថាន់** ព្រមទាំងកូន ១០.០០០៛
- លោក **ជុំ សុផល** ព្រមទាំងកូន ១០.០០០៛

- លោក **សៅ សម** លោកយាយ **ហ៊ុល ហាច** ជូនរៀន ១០.០០០៛
- សីលវតី **ទិត រ៉ុម** ១០.០០០៛
- ឧ.សិ. **ហ៊ឹ សំបូរ**+បុត្រ+ចៅ ១០.០០០៛
- ឧ.សិ.**ខៀវ នាង** ១០.០០០៛
- ឧ.សិ. **នៅ អូន** ១០.០០០៛
- អ្នកស្រី **ម៉ូវ បុប្ផាផល** និងស្វាមី ព្រមទាំងបុត្រ ១០.០០០៛
- ឧ.សិ. **គ្រឿន រី** ១០.០០០៛
- សមណេរ **ចាន់ ឆវន្ត** ១០.០០០៛
- សមណេរ **ឆន សាមិត្ត** ១០.០០០៛
- សីលវតី **សុខ សារឿន** ១០.០០០៛
- លោកអាចារ្យ **ឡើយ** ១០.០០០៛
- ធម្មាចារ្យ **អ៊ុន អ៊ួន** ១០.០០០៛

- លោក **កែវ សារិន** និងលោកស្រី **សេន ម៉ាឡៃ** ១០.០០០៛
- ឧ.សិ. **ឃឹម ឆួន** ១០.០០០៛
- ឧ.សិ. **នាង គៀច** ១០.០០០៛
- លោកយាយ **តា រឿន**+កូន+ចៅ ១០.០០០៛
- ឧ.សិ. **អ៊ុំ អាត** និងកូនចៅ ១០.០០០៛
- លោក **វ៉ន សាន** ឧ.សិ. **សៅ សាវ៉េត** ហៅញិប ១០.០០០៛
- ឧ.ស. **កែន ម៉ុត** ឧ.សិ.**ហ៊ឹម យ៉ុន** +បុត្រ + ចៅ ១០.០០០៛
- លោក **ប៊ុត សារិទ្ធ** និងភរិយា+បុត្រ =១០.០០០៛
- ឧ.សិ.**មុំ វ៉ន** ព្រមទាំងបុត្រ ១០.០០០៛
- លោកយាយ **ថន** ព្រមទាំងបុត្រ ១០.០០០៛

- ឧ.ស. **វៀម សុខុម** ព្រមទាំងភរិយានិងកូនៗ ១០.០០០៛
- លោកយាយ **គង់ ទិន** ១០.០០០៛
- ឧ.សិ. **ជា គឿន** និងស្វាមី+កូន ១០.០០០៛
- ឧ.សិ. **ឆាយ ចណ្ណាធី** ឧ.សិ. សុខ ថុល =១០.០០០៛
- ឧ.ស.**ឡេច** ឧ.សិ.**ជន់** ១០.០០០៛
- ឧ.ស.**ហួន** ឧ.សិ.**អឿច** ១០.០០០៛
- ឧ.ស.**ផន** ឧ.សិ.**ហៀច** ១០.០០០៛
- ឧ.ស.**សាន** ឧ.សិ.**យីន** ១០.០០០៛
- ឧ.សិ.**ភាព** ១០.០០០៛
- ឧ.សិ.**នឿន** ១០.០០០៛
- ឧ.សិ.**សាត** ១០.០០០៛
- ឧ.ស.**ជួន** ឧ.សិ.**អេច** ១០.០០០៛

- លោកយាយ **ញ៉ឹក អ៊ាន** ១០.០០០៛
- សាមណេរ **ឈន ស៊ាងហោ** ១០.០០០៛
- ឧ.សិ.**ម៉ៃ ទី** +បុត្រ ១០០០០៛
- ឧ.ស. **ឡឹ** ឧ.សិ.**ប៊ូ យឿន** ១០.០០០៛
- លោក **មាស ណាសុផុន** ឧ.សិ.**សួន ផល្លី** ព្រមទាំងបុត្រ ១០.០០០៛
- តា ថៃ **លាង** យាយ **ឈុ លី** ១១.០០០៛
- **ញ៉ៀន ធន** ១០.០០០៛
- **ឈុន លី ឡាត់** ១០.០០០៛
- យាយ មឿន ១០.០០០៛
- ឈាង ផៃ ១០.០០០៛
- ផា ឆៃអ៊ាង ១០.០០០៛
- មួត រ៉ាវី ១០.០០០៛
- ឡាត់ ហ៊ាង ១០.០០០៛

- គ្រឹម ដានេ ១០.០០០៛
- លោក **មាស សុធុន** និង**សួន សុផល្លី** ១០.០០០៛
- អ្នកភូមិផ្ទង់ ២១.០០០៛
- ភិក្ខុ **ទូច សារាន**
- ឧ.សិ.**ចេន** ឧ.សិ. **អូក** ឧ.សិ.**មិត្ត**
- ឧ.សិ.**ឈឹម យឿន** ឧ.សិ.**ជឹម ទី**+បុត្រ
- ឧ.សិ. **ហេង ជី** ឧ.សិ.**ឌិន ឈួន** ឧ.សិ.**ធឿន**
- ឧ.ស. **ថុន** ឧ.សិ.**គី គៀន**
- ឧ.សិ. **ផេង នាង**

លោកយាយ **ប៉ាច** លោកតា ស៊ុន,

យាយ **បាន** លោកតា **ឈឹម** យាយ **អ៊ាង**,

**នី ផល**, **ស្រ៊ន់ សុភ**, **ហាក់ ភាព**,

តា ពេញ យាយ **ហ៊ី**, យាយ **យ៉េង**,

យាយ **យ៉ាន**, តា **ស៊ាង**,

លោកតា **ស៊ាន**, បងឆៃរី និងភរិយា,

តា**ស៊ុយ**  យាយ **ហ៊ុន**,

យាយ **អ៊ី**, **មុត** **អឿន**,

យាយ **ឈាង**, យាយ **យ៉ុន**, យាយ **សយ**,

យាយ **សឿន**, **អឿន** **ឡួន**, **អឿន** **លី**,

**ហាន** **សួង**, លោកតា **ឆាន**,

លោកយាយ **ពៅ**, យាយ **សៀក**, យាយ **សួន**,

យាយ **យុន** តា **កេង**, តា **ប៉ុន** និងយាយ,

យាយ **ឡឿន**, យាយ **អ៊ីត**, តា**សូត**

យាយ **ផុន**, យាយ **ខុំ**, យាយ **ហ៊ួយ**

# ឯកសារពិគ្រោះ


១- វចនានុក្រមខ្មែរ

២- បិដកភាគ ១៦, ១៨ និង ៤២

៣- សៀវភៅ ស្រីហិតោបទេស ភាគ១-៤

៤- សៀវភៅ មួយជំហ៊ានម្តង់ Step by Step សម្តេចព្រះមហាឃោសនន្ទ(វ៉ា យ៉ាវ)

៥- ពរ៤ប្រការ (អគបណ្ឌិត ប៊ុត សាវង្ស)

៦- ព្រះបាទធម្មិក (ហេង មណីចន្ទា)

៧- សីល៥ (ហេង មណីចន្ទា)

៨- វាចាមាសពីសេតវិមាន(គឹម ចាន់ណា)

៩- និងឯកសារជាច្រើនទៀត...។

បញ្ញាបញ្ញើស្អាតព្រោះមានរោម
សត្វល្អងសមល្មមដោយស្បែកស្រកា
ដំរីគោសេះល្អព្រោះខ្លាំងក្លា
មនុស្សក្នុងលោកាល្អព្រោះសីលធម៌។

## លំហូរនៃអសីលធម៌

1. អសីលធម៌
2. កំណាញ់មិនចែកទាន
3. លួច
4. ផលិតអាវុធ
5. សម្លាប់
6. កុហក
7. ចាក់ចុច
8. ខុសប្រពៃណី
9. និយាយអាក្រក់ និយាយមិនបានការ
10. គិតចង់បានរបស់គេ គិតព្យាបាទគេ
11. យល់ខុស
12. អធម្មរាគៈ វិសមលោភៈ មិច្ឆាធម្មៈ
13. គ្មានការគោរព
14. ពលរឹសម្បូរថយចុះ

9 789996 283803